# ខចែង និងលក្ខខណ្ឌនៃទំនិញ និងសេវាកម្ម

## 1. និយមន័យ

1.1 ពាក់ព័ន្ធនឹងខចែង និងលក្ខខណ្ឌដែលកំណត់ខាងក្រោម (តទៅនេះហៅថា "លក្ខខណ្ឌ") ពាក្យពេចន៍ខាងក្រោមត្រូវតែមានអត្ថន័យដូចតទៅ៖

(i) "**ទំនិញ**" មានន័យថាវត្ថុបរិ

(ii) "**សេវាកម្ម**" មានន័យរួមមានជាអាទ៍ ការដំឡើង ការថែទាំ និងប្រភេទសេវាកម្មផ្អែកលើពលកម្មផ្សេងទៀត

(iii) "**កិច្ចសន្យា**" មានន័យថាជាកិច្ចព្រមព្រៀងពាក់ព័ន្ធនឹងការផ្គត់ផ្គង់ទំនិញ និង/ឬសេវាកម្មដល់អ្នកទិញដោយអ្នកលក់ដែលធ្វើឡើងស្របតាមប័ណ្ណបញ្ជាទិញ និង/ឬប័ណ្ណការងារដែលចេញដោយអ្នកទិញស្របតាមលក្ខខណ្ឌ

(iv) "**ប័ណ្ណបញ្ជាទិញ**" មានន័យថាជាការបញ្ជាទិញទំនិញក្នុងចំនួនជាក់លាក់តាមការតម្រូវរបស់អ្នកទិញពីពេលមួយទៅពេលមួយដែលអ្នកទិញដាក់ជូនអ្នកលក់ស្របតាមលក្ខខណ្ឌ ហើយប័ណ្ណបញ្ជាទិញត្រូវតែបង្កើតឡើងតាមភាពសមស្រប

(v) "**ធនាគារ អ**"**ប៊ី.អេច.** មានន័យថាជា ធនាគារ អក.ម (ខេមបូឌា) ប៊ី.អេច. នៃក្រុមហ៊ុន

(vi) "**នីតិវិធីគ្រប់គ្រងគុណភាព**" មានន័យថាជាព័ត៌មានលម្អិតអំពីនីតិវិធីគ្រប់គ្រងគុណភាពទំនិញរបស់អ្នកទិញ ដែលត្រូវតែជម្រាបជូន និងជូនដំណឹងដល់អ្នកលក់នៅពេលណាមួយ និងពីពេលមួយទៅពេលមួយ រួមមានជាអាទ៍ដូចខាងក្រោម៖

(ក) ទំនិញត្រូវតែមិនមានវិការៈ (បង្ហាញឱ្យឃើញជាក់ស្តែង ឬលាក់កំបាំង) ទៅលើសម្ភារៈ និងទឹកដៃការងារ

(ខ) អនុលោមតាមលក្ខណៈបច្ចេកទេស គំនូសប្លង់ សេចក្តីពណ៌នាដែលបានផ្តល់ជូននៅក្នុងសម្រង់តម្លៃ ការប៉ាន់ស្មាន ខិត្តប័ណ្ណ ការលក់ ការធ្វើទីផ្សារ និងការបង្រៀន ឬឯកសារអំពីបច្ចេកទេស (មិនថានៅក្នុងទម្រង់ណាមួយក៏ដោយដែលផ្តល់ជូនដល់អ្នកផ្គត់ផ្គង់) ដែលផ្គត់ផ្គង់ដោយ ឬជំនួសមុខឱ្យអ្នកផ្គត់ផ្គង់

(គ) មិនមានវិការៈពីការរចនា និង

(ឃ) សមស្របតាមគោលបំណងរំពឹងទុករបស់អ្នកទិញ ដែលអ្នកទិញបានជូនដំណឹងដល់អ្នកលក់ជាលាយលក្ខណ៍អក្សរ។ អ្នកលក់ទទួលស្គាល់ និងយល់ព្រមដោយមិនអាចលុបចោលវិញបាន និងឥតលក្ខខណ្ឌថា ការអនុម័តដោយអ្នកទិញចំពោះការរចនានានាដែលអ្នកលក់បានផ្តល់ជូន នឹងមិនលើកលែងអ្នកលក់ពីកាតព្វកិច្ចណាមួយរបស់ខ្លួននៅក្រោមប្រការនេះ។

(vii) "**ប័ណ្ណការងារ**" មានន័យថាជាសំណើ ឬការបញ្ជាទិញដែលអ្នកទិញដាក់ជូនអ្នកលក់ចំពោះសេវាកម្ម (អាស្រ័យលើលក្ខខណ្ឌតម្រូវរបស់អ្នកទិញពីពេលមួយទៅពេលមួយ) ស្របតាមលក្ខខណ្ឌនេះ ហើយប័ណ្ណការងារត្រូវបង្កើតឡើងតាមការសមស្រប។

(viii) "អ្នកទិញផ្សេងទៀត" មានន័យថាជាអង្គភាពផ្សេងទៀតនៅក្នុង ធនាគារ អ.អេច.ប៊ី នៃក្រុមហ៊ុនដែលក៏ទទួលបានទំនិញ ឬសេវាកម្មផ្គត់ផ្គង់ដោយអ្នកលក់ផងដែរ តាមការបញ្ជាក់របស់អ្នកទិញយោងទៅតាមកិច្ចសន្យា។

(ix) "អ្នកទិញ" មានន័យថាជាអង្គភាពនៅក្នុងធនាគារ អ.អេច.ប៊ី ដែលឱ្យអ្នកលក់ចូលរួមដើម្បីផ្គត់ផ្គង់ទំនិញ ឬសេវាកម្មយោងទៅតាមលក្ខខណ្ឌនេះ និងប័ណ្ណបញ្ជាទិញ។

(x) "**អ្នកលក់**" មានន័យថាជាអ្នកម៉ៅការដែលចាត់តាំងដោយអ្នកទិញដែលផ្គត់ផ្គង់ទំនិញ ឬសេវាកម្មដល់អ្នកទិញ និង/ឬអ្នកទិញផ្សេងទៀត និងប័ណ្ណបញ្ជាទិញ។

(xi) "**គូភាគី** "មានន័យថា អ្នកលក់ និង ធនាគារ អ.អេច.ប៊ី។

## 2. ការគ្រប់គ្រងគុណភាព

2.1 នីតិវិធីគ្រប់គ្រងគុណភាពទាំងអស់ដែលចេញដោយអ្នកទិញនៅពេលណាមួយ និងពីពេលមួយទៅពេលមួយ ត្រូវតែបង្កើតបានជាផ្នែកមួយនៃលក្ខខណ្ឌទាំងនេះ។

2.2 ប្រសិនបើ៖-

(ក) នីតិវិធីគ្រប់គ្រងគុណភាពដំបូងមិនអនុលោមតាម ឬបំពេញតាមការពេញចិត្តរបស់អ្នកទិញ ឬ

(ខ) នៅពេលណាមួយបន្ទាប់ពីនោះ នីតិវិធីគ្រប់គ្រងគុណភាពជាបន្តបន្ទាប់គឺមិនអនុលោមតាមការពេញចិត្ត ឬបំពេញតាមការពេញចិត្តរបស់អ្នកទិញ នោះអ្នកទិញនឹងបញ្ចប់ផ្នែកទាំងមូល ឬផ្នែកណាមួយដែលមិនបានបំពេញតាមនៃកិច្ចសន្យាពាក់ព័ន្ធណាមួយនៅពេលណាមួយដោយមិនមានកាតព្វកិច្ចបន្ថែម ដល់អ្នកលក់ក្រៅពីការទូទាត់ចំពោះទំនិញ និង/ឬសេវាកម្មណាមួយដែលអ្នកទិញបានទទួលពីអ្នកលក់ និងដែលអ្នកទិញមិនបដិសេធយោងតាមបញ្ញត្តិនៃលក្ខខណ្ឌនេះ។

2.3 អ្នកលក់ ត្រូវផ្តល់សិទ្ធិចេញចូលដល់អ្នកតំណាងរបស់អ្នកទិញនៅគ្រប់ពេលសមស្របទាំងអស់ទៅកាន់បរិវេណរបស់អ្នកលក់ ឬបរិវេណណាមួយដែលជាកន្លែងផលិត កែច្នៃ វេចខ្ចប់ រក្សាទុក ឬប្រមូលទំនិញ និង/ឬសេវាកម្ម ឬសម្ភារៈណាមួយផ្សេងទៀត សម្រាប់គោលបំណងនៃការធ្វើអធិការកិច្ច និងត្រួតពិនិត្យសម្ភារៈដែលប្រើប្រាស់នៅក្នុងដំណើរការផលិត កែច្នៃ វេចខ្ចប់ រក្សាទុក និងប្រមូលផ្តុំទំនិញដែលផ្គត់ផ្គង់ ឬត្រូវផ្គត់ផ្គង់ទៅកាន់អ្នកទិញ។

2.4 ដោយមិនគិតពីការធ្វើអធិការកិច្ច ឬការត្រួតពិនិត្យដោយអ្នកទិញស្របតាមលក្ខខណ្ឌ 3.3 ការធ្វើអធិការកិច្ច ឬការត្រួតពិនិត្យនោះ មិនត្រូវលើកលែងអ្នកទិញពីទំនួលខុសត្រូវ ឬកាតព្វកិច្ចនៅក្រោមលក្ខខណ្ឌទាំងនេះ ឬមិនមានន័យថាជាការទទួលយកទំនិញដោយអ្នកទិញនោះទេ។

2.5 អ្នកទិញត្រូវមានសិទ្ធិអនុវត្តការធ្វើតេស្តណាមួយ ឬនីតិវិធីផ្សេងទៀតមិនថានៅបរិវេណរបស់អ្នកលក់ ឬកន្លែងណាផ្សេងទេ ទៅលើទំនិញ ឬសម្ភារៈណាមួយដែលត្រូវយកទៅផលិត កែច្នៃ វេចខ្ចប់ រក្សាទុក ឬប្រមូលទំនិញតាមការចាំបាច់របស់អ្នកទិញក្នុងការអនុវត្តដូច្នេះ។ ថ្លៃចំណាយនៃការធ្វើតេស្ត ការធ្វើសវនកម្ម ការពិនិត្យ ឬការវាយតម្លៃនេះ ជាបន្ទុករបស់អ្នកលក់ ហើយអ្នកលក់ត្រូវទូទាត់ទឹកប្រាក់នោះនៅពេលដែលអ្នកទិញជូនដំណឹងដល់អ្នកលក់ភ្លាមអំពីការទាមទារថ្លៃចំណាយនោះ។

## 3. **ភាតព្វកិច្ចមិនមែនផ្តាច់មុខ**

គូភាគីសូមទទួលស្គាល់ថា មិនមានប្រការណាមួយនៅក្នុងឯកសារនេះ ត្រូវដាក់កាតព្វកិច្ចណាមួយទៅលើអ្នកទិញឱ្យទិញទំនិញ និង/ឬសេវាកម្ម ឬផ្នែកណាមួយនៃទំនិញ និង/ឬសេវាកម្មនោះដោយផ្តាច់មុខពីអ្នកលក់ឡើយ។

## 4. **ការវេចខ្ចប់** (**សម្រាប់ទំនិញប៉ុណ្ណោះ**)

អ្នកលក់ត្រូវផ្តល់ជូនការវេចខ្ចប់ឱ្យបានត្រឹមត្រូវ និងគ្រប់គ្រាន់ស្របតាមការអនុវត្តពាណិជ្ជកម្មល្អដែលមានអាទិភាព ដើម្បីធានាបានថាសម្ភារៈដែលបានដឹកជញ្ជូនទៅឱ្យអ្នកទិញគឺមិនមានការខូចខាត។ អ្នកលក់ត្រូវខិតខំប្រឹងប្រែងឱ្យបានសមស្របតាមលក្ខណៈពាណិជ្ជកម្ម ដើម្បីប្រើប្រាស់សម្ភារៈវេចខ្ចប់ដែលបានកែច្នៃ និង/ឬអាចកែច្នៃឡើងវិញបាន។ ការចំណាយនានាដែលកើតឡើងចំពោះអ្នកលក់ ដោយសារតែការមិនអនុលោមរបស់អ្នកលក់តាមការណែនាំ នឹងត្រូវជាបន្ទុករបស់អ្នកលក់។ អ្នកទិញរក្សាសិទ្ធិក្នុងការបដិសេធទំនិញណាមួយ ឬទាំងអស់ដែលអ្នកទិញចាត់ទុកថាមានការវេចខ្ចប់មិនបានគ្រប់គ្រាន់។ រាល់ការវេចខ្ចប់ និងការដឹកជញ្ជូនទំនិញដែលបានវេចខ្ចប់រួចនោះទាំងអស់ ត្រូវតែជាចំណាយរបស់អ្នកលក់ លើកលែងតែមានបញ្ជាក់ផ្សេងពីនេះដោយអ្នកទិញ។

## 5. **ការប្រឡាក់** (**សម្រាប់ទំនិញប៉ុណ្ណោះ**)

5.1 ក្នុងករណីដែលទំនិញណាមួយដែលផ្គត់ផ្គង់ដោយអ្នកលក់ (មិនថាទំនិញនោះត្រូវបានដឹកជញ្ជូនទៅឱ្យអ្នកទិញរួចហើយក្តី) គឺត្រូវបានរកឃើញថាមានការប្រឡាក់មិនថាដោយចេតនា ឬអចេតនានៅមុនពេលដឹកជញ្ជូនទៅដោយអ្នកលក់ ដោយមិនមានទំនួលខុសត្រូវបន្ថែមចំពោះអ្នកលក់ នោះអ្នកទិញត្រូវមានសិទ្ធិ៖-

(ក) ផ្អាកការដឹកជញ្ជូន និង/ឬ

(ខ) បញ្ចប់កិច្ចសន្យា និង/ឬ

(គ) តម្រូវឱ្យអ្នកផ្គត់ផ្គង់ប្រមូលស្តុកណាមួយដែលអ្នកទិញបានស្តុកទុកដោយហានិភ័យ និងចំណាយផ្ទាល់ខ្លួនរបស់អ្នកលក់

ទំនិញនានាដែលប្រឡាក់ និង/ឬទំនិញណាមួយដែលពណ៌នាដូចគ្នាទៅនឹងទំនិញដែលប្រឡាក់ និង/ឬទំនិញណាមួយផ្សេងទៀតដែលផ្គត់ផ្គង់ដោយអ្នកផ្គត់ផ្គង់ ការលក់បន្តនៃទំនិញនោះដែលតាមឆន្ទានុសិទ្ធិផ្តាច់មុខរបស់ខ្លួន អ្នកទិញចាត់ទុកថា ឬនឹងមិនអាចចំណេញបាន ជាលទ្ធផលនៃការប្រឡាក់នោះ ហើយអ្នកទិញត្រូវតែរួចផុតពីកាតព្វកិច្ចទូទាត់នានាដែលបានកើតឡើង និងត្រូវតែមានសិទ្ធិទទួលបានការសងប្រាក់ត្រលប់មកវិញគ្រប់ចំនួននូវចំនួនទឹកប្រាក់ណាមួយដែលបានទូទាត់សម្រាប់ទំនិញនោះ។

5.2 សម្រាប់គោលបំណងនៃលក្ខខណ្ឌ 5.1 ទំនិញនឹងត្រូវចាត់ទុកថាប្រឡាក់ក្នុងករណីដែលទំនិញនោះមានផ្ទុកសារធាតុណាមួយ ឬមានគុណភាពណាមួយ ឬតាមមតិរបស់អ្នកទិញ ទំនិញនោះមានគ្រោះថ្នាក់ជាក់ស្តែង ឬអាចនឹងមានគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់ ឬធ្វើឱ្យការលក់បន្តនៃទំនិញនោះជាលក្ខណៈពាណិជ្ជកម្មមិនមានការចំណេញ ឬក្នុងករណីមានការអះអាងពីបុគ្គលណាមួយថាទំនិញនោះត្រូវបានរាំងពីការផ្សព្វផ្សាយជាសាធារណៈ។

## 6. **ការអនុវត្តសេវាកម្ម**

6.1 អ្នកលក់ ត្រូវចាប់ផ្តើម និងបំពេញសេវាកម្មតាមកាលបរិច្ឆេទដែលបានកំណត់ដោយអ្នកទិញ ដូចមានចែងនៅក្នុងកិច្ចសន្យា ឬបំពេញតាមកាលបរិច្ឆេទផ្សេងទៀតដូចបានព្រមព្រៀងគ្នាដោយគូភាគី ហើយអ្នកលក់ត្រូវតែប្រកាន់ឱ្យបានខ្ជាប់ខ្ជួនតាមកាលបរិច្ឆេទនោះ។

6.2 អ្នកទិញរក្សាសិទ្ធិក្នុងការកែសម្រួលកាលបរិច្ឆេទ និង/ឬទីកន្លែងពីពេលមួយទៅពេលមួយសម្រាប់ការផ្គត់ផ្គង់សេវាណាមួយដោយផ្តល់នូវការជូនដំណឹងសមស្របទៅដល់អ្នកលក់។

6.3 គូភាគីព្រមព្រៀងថា ពេលវេលាត្រូវជាចំណុចសំខាន់នៃកិច្ចសន្យានីមួយៗ។ ការខកខានរបស់អ្នកលក់ក្នុងការបំពេញសេវាកម្មនៅកាលបរិច្ឆេទដែលបានបញ្ជាក់ ឬបានជូនដំណឹង ឬបញ្ជាក់បន្ថែម ឬជូនដំណឹងដោយអ្នកទិញ ដោយមិនគិតអំពីសិទ្ធិ ឬឧបាស្រ័យណាមួយរបស់អ្នកទិញ នោះអ្នកទិញមានសិទ្ធិបដិសេធសេវាកម្មទាំងនោះ និង/ឬបញ្ចប់ផ្នែកទាំងមូល ឬផ្នែកណាមួយដែលមិនបានបំពេញនៃកិច្ចសន្យាដែលស្របតាមកិច្ចសន្យានេះ សេវាកម្មនោះត្រូវតែផ្តល់ដោយមិនមានទំនួលខុសត្រូវបន្ថែមរបស់អ្នកទិញចំពោះអ្នកលក់ឡើយ ឬប្រសិនបើអ្នកទិញនៅតែមានចំណាប់អារម្មណ៍បន្តសេវាកម្ម នោះអ្នកទិញរក្សាសិទ្ធិរបស់ខ្លួនក្នុងការទទួលបានការសងថ្លៃខូចខាតពីអ្នកលក់ តាមភាគរយដែលគណនាផ្អែកលើតម្លៃសរុបនៃសេវាកម្មដែលជាប់កិច្ចសន្យាចំពោះការខកខានបំពេញសេវាកម្មនោះក្នុងអំឡុងពេលនៃកិច្ចសន្យាដូចមានចែងនៅក្នុងប័ណ្ណបញ្ជាទិញ និង/ឬប័ណ្ណការងារពាក់ព័ន្ធ។ សំណងខូចខាតនេះ ត្រូវរួមបញ្ចូលការគិតថ្លៃរដ្ឋបាល 10% ទៅលើភាពលម្អៀង និងថ្លៃធ្វើដំណើរពាក់ព័ន្ធនឹងលទ្ធកម្មជំនួស ឬចំនួនទឹកប្រាក់អប្បបរមា KHR46,000.00/USD11.50 ដោយយកតាមអត្រាណាមួយខ្ពស់ជាង ប្រសិនបើពាក់ព័ន្ធ។

6.4 ក្នុងករណីដែលអ្នកលក់មិនអាចបំពេញសេវាកម្មបាននៅកាលបរិច្ឆេទជាក់លាក់ដែលបានបញ្ជាក់ដោយអ្នកទិញ និងលុះត្រាណាតែអ្នកលក់ស្នើសុំ និងអ្នកទិញយល់ព្រមបន្តរយៈពេលសម្រាប់ការបំពេញសេវាកម្ម នោះអ្នកលក់ត្រូវតែបំពេញសេវាកម្មនៅមុនពេលផុតកំណត់រយៈពេលដែលបន្តនោះ ដែលការខកខានបំពេញក្នុងរយៈពេលនេះ អ្នកទិញត្រូវមានសិទ្ធិបញ្ចប់ផ្នែកទាំងមូល ឬផ្នែកណាមួយដែលមិនបានបំពេញនៃកិច្ចសន្យានេះដោយមិនទទួលខុសត្រូវលើប្រការណាមួយចំពោះអ្នកលក់ឡើយ។

6.5 លើកលែងតែមានចែងផ្ទុយពីកិច្ចសន្យា អ្នកទិញមិនមានកាតព្វកិច្ចទទួលយកការបញ្ចប់សេវាកម្មតាមដំណាក់កាលនោះទេ។ ប៉ុន្តែ តាមឆន្ទានុសិទ្ធិរបស់ខ្លួន ប្រសិនបើអ្នកទិញមិនបានបញ្ជាក់ ឬយល់ព្រមទទួលការបញ្ចប់សេវាកម្មតាមដំណាក់កាល ការបញ្ចប់ដំណាក់កាលណាមួយនៃសេវាកម្មយឺតជាងកាលបរិច្ឆេទដែលបានបញ្ជាក់ ឬព្រមព្រៀង ដោយមិនគិតទៅលើសិទ្ធិ ឬឧបាស្រ័យណាមួយផ្សេងទៀតរបស់អ្នកទិញ នោះអ្នកទិញត្រូវមានសិទ្ធិបញ្ចប់ផ្នែកទាំងមូល ឬផ្នែកណាមួយនៃកិច្ចសន្យាដោយអ្នកទិញមិនទទួលខុសត្រូវបន្ថែមចំពោះអ្នកលក់ឡើយ។

6.6 អ្នកលក់ត្រូវធានាថា នៅគ្រប់ទិដ្ឋភាពទាំងអស់ សេវាកម្មអនុលោមតាមលក្ខខណ្ឌតម្រូវពាក់ព័ន្ធទាំងអស់នៃលក្ខន្តិកៈ វិធាន ឬបញ្ជាតាមបញ្ញត្តិ ឬលិខិតូបករណ៍ផ្សេងៗនៃច្បាប់ជាធរមាន ដែលអាចនឹងមានប្រសិទ្ធភាពនៅក្នុងការផ្តល់សេវាកម្ម។

6.7 អ្នកលក់សូមទទួលស្គាល់ និងព្រមព្រៀងដោយមិនអាចលុបចោលវិញបាន និងឥតលក្ខខណ្ឌថា អ្នកទិញអាចជូនដំណឹងដល់អ្នកលក់ជាលាយលក្ខណ៍អក្សរអំពីការប្រែប្រួលចំពោះសេវាកម្មនៅពេលណាមួយក៏បាន។ ប្រសិនបើការប្រែប្រួលនាំឱ្យមានការកើនឡើងចំពោះវិសាលភាពនៃសេវាកម្មដែលនឹងត្រូវអនុវត្ត នោះថ្លៃចំណាយដែលត្រូវទូទាត់ និងរយៈពេលសម្រាប់ការបញ្ចប់សេវាកម្មនោះ ត្រូវតែកែសម្រួល ដែលការកែសម្រួលនោះត្រូវតែស្របតាមលក្ខខណ្ឌដែលមានការព្រមព្រៀងរវាងគូភាគី។

## 7. ការប្រគល់

7.1 ក្នុងករណីដែលកាលបរិច្ឆេទ និងអាសយដ្ឋានសម្រាប់ការប្រគល់ទំនិញគឺមានបញ្ជាក់នៅក្នុងកិច្ចសន្យា និង/ឬក្នុងករណីដែលអ្នកទិញមានសិទ្ធិ និងជូនដំណឹងដល់អ្នកលក់ពីពេលមួយទៅពេលមួយអំពីកាលបរិច្ឆេទ និងអាសយដ្ឋានប្រគល់ កាលបរិច្ឆេទ និងអាសយដ្ឋាននោះត្រូវតែប្រកាន់ខ្ជាប់ឱ្យបានតឹងរ៉ឹងដោយអ្នកលក់។

7.2 អ្នកទិញរក្សាសិទ្ធិក្នុងការកែសម្រួលកាលបរិច្ឆេទ និង/ឬទីកន្លែងពីពេលមួយទៅពេលមួយសម្រាប់ការប្រគល់ទំនិញណាមួយដោយផ្តល់នូវការជូនដំណឹងសមស្របទៅដល់អ្នកលក់។

7.3 គូភាគីព្រមព្រៀងថា ពេលវេលាត្រូវជាចំណុចសំខាន់នៃកិច្ចសន្យានីមួយៗ។ ការខកខានប្រគល់ទំនិញនៅកាលបរិច្ឆេទ និងអាសយដ្ឋានដែលបានបញ្ជាក់ ឬជូនដំណឹង ឬបញ្ជាក់បន្ថែម ឬជូនដំណឹងបន្ថែម ដោយមិនគិតអំពីសិទ្ធិ និងឧបាស្រ័យណាមួយផ្សេងទៀតរបស់អ្នកទិញ នោះអ្នកទិញមានសិទ្ធិ៖-

(ក) បដិសេធទំនិញទាំងនោះ និង/ឬបញ្ចប់ផ្នែកទាំងមូល ឬផ្នែកណាមួយដែលមិនបានបំពេញនៃកិច្ចសន្យា ដែលស្របតាមកិច្ចសន្យានោះ ទំនិញត្រូវតែប្រគល់ដោយអ្នកទិញមិនមានទំនួលខុសត្រូវបន្ថែមចំពោះអ្នកលក់ឡើយ ឬ

(ខ) ទិញទំនិញដូចគ្នា ឬស្រដៀងគ្នាពីអ្នកលក់ផ្សេងទៀត និង

(គ) ទារយកមកវិញនូវធាតុនៃថ្លៃដើមលើការទិញទំនិញពីអ្នកលក់ផ្សេងទៀតដែលហួសពីតម្លៃដើម ឬ

ប្រសិនបើអ្នកទិញនៅតែមានចំណាប់អារម្មណ៍ទទួលយកទំនិញ នោះអ្នកទិញរក្សាសិទ្ធិរបស់ខ្លួនក្នុងការទទួលបានការសងថ្លៃខូចខាតពីអ្នកលក់តាមភាគរយដែលគណនាផ្អែកលើតម្លៃសរុបនៃទំនិញដែលបានទិញ ចំពោះការខកខានប្រគល់ទំនិញនៅកាលបរិច្ឆេទប្រគល់ដែលបានកំណត់ទុកជាមុនដូចមានចែងនៅក្នុងប័ណ្ណបញ្ជាទិញ និង/ឬប័ណ្ណការងារពាក់ព័ន្ធ។ សំណងខូចខាតនេះ ត្រូវរួមបញ្ចូលការគិតថ្លៃរដ្ឋបាល 10% ទៅលើភាពលម្អៀង និងថ្លៃធ្វើដំណើរពាក់ព័ន្ធនឹងលទ្ធកម្មជំនួស ឬចំនួនទឹកប្រាក់អប្បបរមា KHR46,000.00/USD11.50 ដោយយកតាមអត្រាណាមួយខ្ពស់ជាង ប្រសិនបើពាក់ព័ន្ធ។

7.4 ក្នុងករណីដែលអ្នកលក់មិនអាចបំពេញតាមកាលបរិច្ឆេទប្រគល់ទំនិញ និងលុះត្រាណាតែអ្នកលក់ស្នើសុំ និងអ្នកទិញយល់ព្រមបន្តរយៈពេលសម្រាប់ការប្រគល់ទំនិញ នោះអ្នកលក់ត្រូវតែប្រគល់ទំនិញនៅមុនពេលផុតកំណត់រយៈពេលដែលបន្តនោះ ដែលការខកខានបំពេញក្នុងរយៈពេលនេះ អ្នកទិញត្រូវមានសិទ្ធិចាត់ឧបាស្រ័យដូចមានចែងនៅក្នុងប្រការ 7.3។

7.5 លើកលែងតែមានចែងផ្ទុយពីកិច្ចសន្យា អ្នកទិញមិនមានកាតព្វកិច្ចទទួលយកការប្រគល់ទំនិញតាមដំណាក់កាលនោះទេ។ ប៉ុន្តែ តាមឆន្ទានុសិទ្ធិរបស់ខ្លួន ប្រសិនបើអ្នកទិញមិនបានបញ្ជាក់ ឬយល់ព្រមទទួលការប្រគល់ទំនិញតាមដំណាក់កាល ការប្រគល់ទំនិញនៅដំណាក់កាលណាមួយយឺតជាងកាលបរិច្ឆេទដែលបានបញ្ជាក់ ឬព្រមព្រៀង ដោយមិនគិតទៅលើសិទ្ធិ ឬឧបាស្រ័យណាមួយផ្សេងទៀតរបស់អ្នកទិញ នោះអ្នកទិញត្រូវមានសិទ្ធិបញ្ចប់ផ្នែកទាំងមូល ឬផ្នែកណាមួយនៃកិច្ចសន្យា ដោយអ្នកទិញមិនទទួលខុសត្រូវបន្ថែមចំពោះអ្នកលក់ឡើយ។

7.6 ពាក់ព័ន្ធនឹងកិច្ចសន្យាទាំងអស់ ដែលនៅក្រោមកិច្ចសន្យាទាំងនេះទំនិញគឺត្រូវបានផ្គត់ផ្គង់ លើកលែងតែមានការព្រមព្រៀងគ្នាដោយអ្នកទិញផ្ទុយពី៖-

(ក) ទំនិញត្រូវតែប្រគល់ ដឹកជញ្ជូន និងបង់ពន្ធអាករទៅកាន់អាសយដ្ឋានសម្រាប់ការប្រគល់ដែលបានជូនដំណឹងដល់អ្នកលក់

(ខ) អ្នកលក់ត្រូវធានាលើទំនិញចំពោះទឹកប្រាក់ស្មើនឹង 125% នៃតម្លៃកិច្ចសន្យាសម្រាប់ទំនិញ ឬសម្រាប់ចំនួនទឹកប្រាក់ផ្សេងទៀតតាមការបញ្ជាក់ដោយអ្នកទិញ នៅក្រុមហ៊ុនធានារ៉ាប់រងម៉ាឡេស៊ីដែលមានកេរ្តិ៍ឈ្មោះដែលបានជូនដំណឹងពីមុនទៅកាន់ និងព្រមព្រៀងដោយអ្នកទិញ ចំពោះហានិភ័យទាំងអស់ រួមមានជាអាទិ៍ ការលួចឆក់ប្លន់ និងការមិនប្រគល់ដោយសារតែមូលហេតុណាមួយពីចំណុចផលិតកម្ម ដល់ទិសដៅចុងក្រោយនៅក្នុងប្រទេសកម្ពុជា តាមរយៈការដឹកជញ្ជូនតាមផ្លូវសមុទ្រ ផ្លូវអាកាស ផ្លូវគោក ផ្លូវដែក ឬមធ្យោបាយដឹកជញ្ជូនណាមួយផ្សេងទៀត

(គ) ការទូទាត់ត្រូវធ្វើឡើងជារូបិយប័ណ្ណ រីងហ្គីត ដើម្បីជាថ្នូរនឹងឯកសារត្រឹមត្រូវ

(ឃ) ទំនិញទាំងអស់ ត្រូវតែអមជាមួយនឹងឯកសារប្រគល់ទំនិញនៅក្នុងទម្រង់មួយ និងមានផ្ទុកលេខប័ណ្ណបញ្ជាទិញ និងព័ត៌មានលម្អិតផ្សេងទៀត ត្រូវតែជូនដំណឹងដល់អ្នកលក់ពីពេលមួយទៅពេលមួយរួមជាមួយនឹងឯកសារពាក់ព័ន្ធផ្សេងទៀតតាមការតម្រូវដោយអ្នកទិញពីពេលមួយទៅពេលមួយ។

(ង) អ្នកទិញនឹងមិនប្រគល់ត្រលប់ទៅវិញនូវចំនួនទឹកប្រាក់ណាមួយ ឬបុព្វលាភណាមួយដែលបានទូទាត់សម្រាប់ការធានារ៉ាប់រងដែលបានទិញជូនដល់អ្នកទិញស្របតាមប្រការ 7.6(ខ) ខាងលើ។

7.7 ហត្ថលេខារបស់អ្នកទិញដែលបានចុះនៅលើឯកសារប្រគល់ទំនិញ ឬឯកសារផ្សេងៗ ដែលតំណាងឱ្យហត្ថលេខាពាក់ព័ន្ធនឹងការប្រគល់ទំនិញ គឺជាភស្តុតាងតែមួយគត់នៃចំនួនទំនិញដែលបានទទួល។ ជាពិសេស ហត្ថលេខានេះ មិនមែនជាភស្តុតាងបញ្ជាក់ថាបរិមាណ ឬចំនួនទំនិញត្រឹមត្រូវត្រូវបានប្រគល់ ឬថាទំនិញដែលបានប្រគល់នោះគឺមានស្ថានភាពល្អ ឬមានបរិមាណត្រឹមត្រូវនោះទេ។

7.8 អ្នកលក់ត្រូវធានាថា នៅគ្រប់ទិដ្ឋភាពទាំងអស់ ទំនិញអនុលោមតាមលក្ខខណ្ឌតម្រូវពាក់ព័ន្ធទាំងអស់នៃលក្ខន្តិកៈ វិធាន ឬបញ្ជាតាមបញ្ញត្តិ ឬលិខិតូបករណ៍ផ្សេងៗនៃច្បាប់ជាធរមាន ដែលអាចនឹងមានប្រសិទ្ធភាពពេលប្រគល់ទំនិញ។

7.9 ប្រសិនបើដោយសារមូលហេតុណាមួយ អ្នកទិញមិនអាចទទួលយកការប្រគល់ទំនិញនៅ ឬបន្ទាប់ពីកាលបរិច្ឆេទប្រគល់ទំនិញដែលបានព្រមព្រៀង អ្នកលក់ត្រូវតែរក្សាទុកទំនិញ ការពារទំនិញទាំងណោះ និងចាត់វិធានការសមស្របទាំងអស់ដើម្បីធានាថា ទំនិញនោះមានស្ថានភាពល្អរហូតដល់ការប្រគល់ដោយចំណាយថ្លៃដើម និងការចំណាយជាបន្ទុករបស់អ្នកលក់។

## 8. កម្មសិទ្ធិ និងហានិភ័យ (សម្រាប់ទំនិញប៉ុណ្ណោះ)

8.1 អ្នកលក់ អះអាង ធានា និងទទួលខុសត្រូវថា៖-

(ក) អ្នកលក់មានកម្មសិទ្ធិពេញលេញ ច្បាស់លាស់ និងមិនជាប់បន្ទុកចំពោះគ្រប់ទំនិញទាំងអស់

(ខ) នៅកាលបរិច្ឆេទប្រគល់ទំនិញ ឬផ្នែកណាមួយនៃទំនិញ អ្នកលក់ត្រូវកាន់កាប់កម្មសិទ្ធិទៅលើទំនិញដូចដែលបានលើកឡើងនៅក្នុងប្រការ 8.1 (ក) ខាងលើ និង

(គ) នៅកាលបរិច្ឆេទប្រគល់ទំនិញ ឬផ្នែកណាមួយនៃទំនិញ អ្នកលក់នឹងមានសិទ្ធិ អំណាច និងសមត្ថកិច្ចពេញលេញ និងមិនមានការរឹតត្បិតក្នុងការលក់ ផ្ទេរ និងប្រគល់ទំនិញទាំងអស់ដល់អ្នកទិញ។ ចាប់ពីកាលបរិច្ឆេទនោះ អ្នកទិញត្រូវតែទទួលបានកម្មសិទ្ធិមានសុពលភាព និងមិនជាប់បន្ទុកចំពោះទំនិញ។

8.2 កម្មសិទ្ធិលើ និងហានិភ័យចំពោះទំនិញណាមួយ ឬផ្នែកណាមួយនៃទំនិញដែលប្រគល់ដល់អ្នកទិញស្របតាមកិច្ចសន្យាត្រូវតែផ្ទេរទៅឱ្យអ្នកទិញនៅពេលប្រគល់ទំនិញដល់អ្នកទិញ ទោះបីជាមានការរក្សាទុកតាមគោលបំណងណាមួយនៃកម្មសិទ្ធិនោះដោយអ្នកលក់រហូតដល់កាលបរិច្ឆេទពេលក្រោយណាមួយ ឬការព្យាយាមរបស់អ្នកលក់ក្នុងការផ្ទេរហានិភ័យនៅកាលបរិច្ឆេទមុននេះ។
ប្រសិនបើទំនិញ ឬផ្នែកណាមួយនៃទំនិញ គឺត្រូវបានបដិសេធជាបន្តបន្ទាប់សម្រាប់ការខកខានមិនបំពេញតាមខចែង និងលក្ខខណ្ឌនៃលក្ខខណ្ឌនេះ និង/ឬលក្ខខណ្ឌទាំងនេះ និង/ឬការខកខានមិនអនុលោមតាមនីតិវិធីគ្រប់គ្រងគុណភាព លក្ខណៈបច្ចេកទេស ឬមូលហេតុណាមួយផ្សេងទៀត នៅពេលមានការជូនដំណឹងជាលាយលក្ខណ៍អក្សរពីអ្នកទិញជូនដល់អ្នកលក់ នោះហានិភ័យចំពោះទំនិញត្រូវតែផ្ទេរត្រលប់ទៅឱ្យអ្នកលក់វិញនៅកាលបរិច្ឆេទនៃការជូនដំណឹងនោះ។

8.3 អ្នកទិញមានសិទ្ធិបដិសេធទំនិញណាមួយដែលបានប្រគល់ដែលលើសពីបរិមាណដែលបានបញ្ជាទិញ ហើយអ្នកលក់តម្រូវឱ្យយកចេញនូវទំនិញដែលប្រគល់លើសនោះ និងទូទាត់ជូនអ្នកទិញនូវការចំណាយណាមួយ និងទាំងអស់ដែលកើតឡើងដោយផ្ទាល់ និងដោយប្រយោលចំពោះអ្នកទិញដែលជាលទ្ធផលនៃការប្រគល់លើសបរិមាណនោះ រួមមានជាអាទ៍ ថ្លៃចំណាយលើការលើកដាក់ និងការរក្សាទុកទំនិញទាំងនោះ។ ទាំងកម្មសិទ្ធិ និងហានិភ័យ គឺមិនត្រូវផ្ទេរទៅកាន់អ្នកទិញទេ ទោះបីជាទំនិញដែលបានប្រគល់លើសនោះនៅតែស្ថិតនៅបរិវេណរបស់អ្នកទិញក៏ដោយ។

8.4 ក្នុងករណីដែលអ្នកលក់ខកខានមិនយកចេញនូវទំនិញ ឬទំនិញណាមួយ នោះអ្នកទិញមានសិទ្ធិ៖-

(ក) ចាត់ចែងទំនិញនោះតាមការសមស្រប ដោយមិនចាំបាច់ជូនដំណឹងបន្ថែមដល់អ្នកផ្គត់ផ្គង់នោះទេ និង

(ខ) កាត់ចេញពីការទូទាត់ណាមួយនៅពេលក្រោយពីអ្នកទិញជូនដល់អ្នកលក់នូវចំនួនទឹកប្រាក់នៃការចំណាយណាមួយដែលកើតឡើងដោយផ្ទាល់ ឬដោយប្រយោលពាក់ព័ន្ធនឹងការលើកដាក់ ការរក្សាទុក ការចាត់ចែង ឬកិច្ចការផ្សេងៗនៃទំនិញដែលប្រគល់លើសបរិមាននោះ។

8.5 ដោយមិនគិតទៅលើភាពទូទៅនៃចំណុចខាងលើ អ្នកផ្គត់ផ្គង់យល់ព្រមទទួលហានិភ័យនៃការធ្លាក់ចុះគុណភាពទំនិញដែលជាហេតុការណ៍ចាំបាច់ចំពោះដំណើរដឹកជញ្ជូនទំនិញឆ្លងកាត់។

## 9. ការទទួលយកទំនិញ និង/ឬសេវាកម្ម

9.1 ការចេញបង្កាន់ដៃទទួលដោយអ្នកទិញចំពោះទំនិញ និង/ឬសេវាកម្មណាមួយ មិនត្រូវបង្កើតជាការទទួលស្គាល់ និង/ឬការទទួលយក ឬចាត់ទុកថាជាការទទួលស្គាល់ និង/ឬការទទួលយកស្ថានភាព ឬលក្ខណៈនៃទំនិញ និង/ឬសេវាកម្មនោះឡើយ។

9.2 ប្រសិនបើអ្នកទិញរកឃើញថាទំនិញ និង/ឬសេវាកម្ម ឬផ្នែកណាមួយនៃទំនិញ និង/ឬសេវាកម្ម៖-

(ក) មិនប្រគល់ស្របតាមកិច្ចសន្យាពាក់ព័ន្ធ ឬ

(ខ) មិនបំពេញតាមលក្ខណៈបច្ចេកទេស ឬគំរូណាមួយ ឬ

(គ) មិនអនុលោមតាមនីតិវិធីគ្រប់គ្រងគុណភាព ឬ

(ឃ) មិនមានគុណភាពអាចលក់បាន ឬមិនសមស្របសម្រាប់គោលបំណងរំពឹងទុក ឬ

(ង) បំពានទៅលើការធានាណាមួយដែលបានផ្តល់ជូនដោយអ្នកលក់នៅក្រោមលក្ខខណ្ឌនេះ ដោយមិនគិតពីបញ្ញត្តិនៃលក្ខខណ្ឌ 9.2 នោះអ្នកទិញត្រូវមានសិទ្ធិ៖

(i) ឃាត់ទុកការទូទាត់ណាមួយដែលត្រូវទូទាត់ជូនអ្នកលក់

(ii) បដិសេធទំនិញ និង/ឬសេវាកម្ម ឬទំនិញណាមួយ និងតម្រូវឱ្យអ្នកលក់យកចេញនូវទំនិញ/សេវាកម្ម ឬផ្នែកណាមួយនៃទំនិញ/សេវាកម្ម និងសងត្រលប់ជូនអ្នកទិញវិញនូវតម្លៃដែលអ្នកទិញបានទូទាត់ជូន រួមជាមួយនឹងថ្លៃចំណាយទាំងអស់ដែលកើតមានដោយផ្ទាល់ ឬដោយប្រយោលចំពោះអ្នកទិញ ដោយសារតែការបដិសេធ ឬការយកចេញនោះ និង

(iii) ចាត់ទុកកិច្ចសន្យា និង/ឬផ្នែកណាមួយដែលមិនបានបំពេញនៃកិច្ចសន្យានោះថាត្រូវបានបដិសេធដោយអ្នកលក់។

## 10. ទំនិញប្រគល់ត្រលប់

10.1 លើកលែងតែព្រមព្រៀងគ្នាផ្សេងពីនេះជាលាយលក្ខណ៍អក្សរ ក្នុងករណីដែលទំនិញណាមួយដែលអ្នកទិញបានយក និងទូទាត់រួចរាល់ ត្រូវបានប្រគល់ត្រលប់មកវិញដោយអ្នកទិញទៅកាន់អ្នកលក់ កម្មសិទ្ធិលើទំនិញទាំងនោះមិនត្រូវផ្ទេរទៅឱ្យអ្នកលក់ទេ និងត្រូវតែនៅជាកម្មសិទ្ធិរបស់អ្នកទិញ រហូតដល់អ្នកលក់បានទូទាត់ជូនអ្នកទិញវិញ (តាមមធ្យោបាយលិខិតឥណទានដែលចេញដោយអ្នកលក់ ឬមធ្យោបាយផ្សេងទៀតដែលទទួលយកបានដោយអ្នកទិញ) នូវទឹកប្រាក់ទាំងអស់ដែលត្រូវទូទាត់នៅក្រោមកិច្ចសន្យានេះ ដែលទំនិញនោះត្រូវបានផ្គត់ផ្គង់ជូន។

10.2 រហូតដល់ពេលនោះ នៅពេលដែលកម្មសិទ្ធិត្រូវបានផ្ទេរទៅកាន់អ្នកលក់ តាមលក្ខណៈមួយដែលមានចែងនៅក្នុងលក្ខខណ្ឌ 10.1 តាមការចំណាយទាំងស្រុងរបស់ខ្លួន អ្នកលក់ត្រូវ៖-

(ក) រក្សាទំនិញនេះដាច់ដោយឡែក និងឆ្ងាយពីទំនិញផ្សេងទៀត រក្សាទុក ការពារ និងធានាឱ្យបានត្រឹមត្រូវធ្វើយ៉ាងណាងាយស្រួលចំណាំបានច្បាស់ថាជាកម្មសិទ្ធិរបស់អ្នកទិញ និង

(ខ) ចាត់វិធានការចាំបាច់ទាំងអស់ ដើម្បីធានាថាអ្នកលក់មិនក្លាយជា និងមិនត្រូវបានចាត់ទុកថាជាម្ចាស់ទំនិញឡើយ

(គ) មិនលក់ ឬចាត់ចែងទំនិញទៅឱ្យភាគីទីបីណាមួយដោយមិនមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរពីអ្នកទិញនោះទេ។

10.3 ប្រសិនបើបំពានលើលក្ខខណ្ឌ 10.2៖-

(ក) អ្នកលក់លក់ទំនិញ ឬ

(ខ) ទំនិញត្រូវបានបំផ្លាញ ខូចខាត ឬបាត់បង់

នោះអ្នកលក់ត្រូវ៖-

(i) (ក្នុងករណីលក់) រក្សាទុកសាច់ប្រាក់ (មិនថាជារូបី ឬអរូបី) នៃការលក់ ឬការចាត់ចែងណាមួយ និងសិទ្ធិ ឬការទាមទារណាមួយទៅលើភាគីទីបីដែលកើតចេញពីការលក់ ឬការចាត់ចែងនោះ ឬ

(ii) (ក្នុងករណីបំផ្លាញ ឬបាត់បង់) ត្រូវរក្សាទុកសាច់ប្រាក់ពីការធានារ៉ាប់រងដែលត្រូវទូទាត់ពាក់ព័ន្ធនឹងការបំផ្លាញ ការខូចខាត ឬការបាត់បង់នោះ

ក្នុងករណីនីមួយៗនៅពេលភ្នាក់ងារទទួលសិទ្ធិ ឬអ្នកធានាសម្រាប់ និងចំពោះបន្ទុករបស់អ្នកទិញ និងត្រូវចាត់វិធានការចាំបាច់ទាំងអស់ ដើម្បីរក្សាសាច់ប្រាក់នោះដាច់ដោយឡែកពីប្រាក់ផ្សេងៗ ទូទាត់សាច់ប្រាក់នោះជូនដល់អ្នកទិញ និងផ្ទេរជូនអ្នកទិញនូវសិទ្ធិ ឬការទាមទារណាមួយទៅលើភាគីទីបីដល់កម្រិតវិសាលភាពដែលចាំបាច់ក្នុងការបញ្ចេញសាច់ប្រាក់ជំពាក់គ្រប់ចំនួនរបស់អ្នកលក់ទៅឱ្យអ្នកទិញ។

10.4 ប្រសិនបើនៅពេលណាមួយ ការទូទាត់ទឹកប្រាក់ដល់កំណត់បង់ជូនដល់អ្នកទិញ ពាក់ព័ន្ធនឹងទំនិញគឺហួសកាលកំណត់នោះអ្នកទិញ តាមរយៈបុគ្គលិក ឬភ្នាក់ងាររបស់ខ្លួន ចូលក្នុងបរិវេណរបស់អ្នកលក់ ព្រមទាំងទាមទារ និងចាត់ចែងទំនិញ ហើយអ្នកលក់មិនត្រូវធ្វើការទាមទារទៅលើអ្នកទិញពាក់ព័ន្ធនឹងការចូល ឬការចាត់ចែងដើម្បីទាមទារយកមកវិញនូវសមតុល្យណាមួយដែលត្រូវបង់ទៅឱ្យអ្នកលក់។

## 11. ការលុបចោលទំនិញ

អ្នកទិញត្រូវមានសិទ្ធិលុបចោលការបញ្ជាទិញចំពោះទំនិញ និង/ឬសេវាកម្ម (ឬផ្នែកណាមួយនៃទំនិញ និង/ឬសេវាកម្ម) ដែលមិនទាន់បានប្រគល់ទៅឱ្យអ្នកទិញ។ ការលុបចោលនេះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។ អ្នកទិញមិនត្រូវទទួលខុសត្រូវចំពោះការពិន័យ ឬផលវិបាកណាមួយដែលកើតចេញពីការការលុបចោលនេះទេ។ នៅពេលធ្វើការលុបចោល អ្នកលក់ត្រូវបញ្ឈប់ការងារភ្លាមៗនៅលើផ្នែកនៃការបញ្ជាទិញដែលបានបញ្ឈប់ និងទូទាត់ជូនវិញនូវទឹកប្រាក់នានាដែលអ្នកទិញបានទូទាត់ជាមុនសម្រាប់គោលបំណងនៃការបញ្ជាទិញនោះ។

**12. បុគ្គលិក**

12.1 ពាក់ព័ន្ធនឹង និងសម្រាប់គោលបំណងនៃការផ្តល់សេវាកម្ម អ្នកទិញត្រូវធានាថា អ្នកទិញមានបុគ្គលិកគ្រប់គ្រាន់ក្នុងការបំពេញសេវាកម្មបានត្រឹមត្រូវ មានប្រសិទ្ធភាព រហ័ស និងស្របតាមលក្ខខណ្ឌ (តទៅនេះហៅថា "បុគ្គលិក") និងត្រូវបន្តធានា/អះអាងថា បុគ្គលិក៖

(ក) អនុវត្តភារកិច្ចពាក់ព័ន្ធបានត្រឹមត្រូវ និងទាន់ពេលវេលា

(ខ) មានគុណវុឌ្ឍិ និងការបណ្តុះបណ្តាលគ្រប់គ្រាន់ដល់កម្រិតជំនាញដែលតម្រូវជាចាំបាច់ដើម្បីអនុវត្តសេវាកម្ម និង

(គ) ផ្តល់សេវានានាប្រកបដោយការយកចិត្តទុកដាក់ ភាពត្រឹមត្រូវ និងមានប្រសិទ្ធភាព មានទឹកដៃល្អ និងមានជំនាញវិជ្ជាជីវៈ ព្រមទាំងប្រឹងប្រែងអស់ពីសមត្ថភាព។

12.2 ដោយមិនគិតទៅលើសិទ្ធិ ឬឧបាស្រ័យណាមួយផ្សេងទៀតដែលមានចំពោះអ្នកទិញ នោះអ្នកទិញមានសិទ្ធិតម្រូវឱ្យអ្នកលក់ដកបុគ្គលិកណាមួយចេញពីសេវាកម្ម ដែលតាមគំនិតរបស់អ្នកទិញ បុគ្គលិកនោះមិនមានសមត្ថភាព បទពិសោធន៍ជំនាញ មានអាកប្បកិរិយាមិនល្អ ដែលទំណងជាគម្រាមកំហែងដល់សន្តិសុខ និង/ឬធ្វេសប្រហែសនៅក្នុងការបំពេញភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវ ហើយអ្នកលក់ត្រូវផ្លាស់ប្តូរបុគ្គលិកដែលបានបញ្ឈប់នោះជាមួយនឹងបុគ្គលិកដែលមានគុណវុឌ្ឍិ និងជំនាញសមស្របដែលអ្នកលក់ពេញចិត្ត ដោយចំណាយនានាគឺជាបន្ទុករបស់អ្នកលក់។

12.3 ក្នុងករណីមានជំងឺ ឬគ្រោះថ្នាក់ដែលរារាំង/ធ្វើឱ្យយឺតយ៉ាវ/អាចមានលទ្ធភាពរារាំង/ធ្វើឱ្យយឺតយ៉ាវដល់ការបំពេញសេវាកម្ម អ្នកទិញមានសិទ្ធិតម្រូវឱ្យអ្នកលក់ផ្លាស់ប្តូរបុគ្គលិកនោះភ្លាមៗ។

**13. ការធានា**

អ្នកលក់ធានាយ៉ាងច្បាស់ថា គ្រប់ទំនិញ និងសេវាកម្មទាំងអស់ដែលបានប្រគល់ ឬបានបំពេញ នឹង៖

(ក) អាចលក់ចេញបាន (សម្រាប់ទំនិញប៉ុណ្ណោះ)

(ខ) មិនមានវិការៈទៅលើសម្ភារៈ និងទឹកដៃការងារ

(គ) សមស្របតាម និងគ្រប់គ្រាន់សម្រាប់គោលបំណងរំពឹងទុក និង

(ឃ) អនុលោមតាមយ៉ាងម៉ឺងម៉ាត់ចំពោះលក្ខណៈបច្ចេកទេស គំនូសប្លង់ពាក់ព័ន្ធដែលបានអណុម័ត។ ការបញ្ជូន ឬសេចក្តីពណ៌នាផ្សេងទៀតដែលផ្តល់ឱ្យដោយអ្នកទិញ។ រាល់ការធានាទាំងអស់ដែលបានបញ្ជាក់នៅក្នុងលក្ខខណ្ឌនេះ ត្រូវតែបន្ថែមចំពោះការធានាដោយផ្ទាល់ តាមបទប្បញ្ញត្តិ ឬដោយប្រយោលផ្សេងទៀត។ ការធានានេះត្រូវបន្តមានសុពលភាពរួចផុតពីការធ្វើអធិការកិច្ច ការទទួលយក និងការទូទាត់របស់អ្នកទិញ ព្រមទាំងការប្រើប្រាស់បន្តរបស់អ្នកទិញចំពោះទំនិញ ឬសេវាកម្មបន្ទាប់ពីជូនដំណឹងដល់អ្នកលក់អំពីការមិនអនុលោមតាម ឬការបំពានរបស់អ្នកលក់ទៅលើការធានា នឹងមិនចាត់ទុកថាជាការលះបង់សិទ្ធិរបស់អ្នកទិញចំពោះឧបាស្រ័យឡើយ។

## 14. ការធានារ៉ាប់រង

ដរាបណាខ្លួននៅតែជាភាគីនៃកិច្ចសន្យានេះជាមួយនឹងអ្នកទិញ អ្នកលក់ត្រូវតែទិញ និងរក្សាធានារ៉ាប់រងសមស្របដោយចំណាយផ្ទាល់ខ្លួនសម្រាប់រយៈពេលនៃកិច្ចសន្យា ដោយមាននូវកម្រិតខាតបង់សមស្របសម្រាប់កិច្ចសន្យានេះ រួមមានការធានារ៉ាប់រងណាមួយដែលតម្រូវដោយច្បាប់នៃប្រទេសចុះបញ្ជី ឬប្រទេសផ្តល់អាជ្ញាប័ណ្ណ និងតម្រូវដោយប្រទេសដែលអនុវត្តការងារ ឬសេវាកម្ម។ នៅពេលមានការស្នើសុំ អ្នកលក់ត្រូវផ្តល់ជូនអ្នកទិញនូវវិញ្ញាបនបត្រធានារ៉ាប់រងចំពោះការធានារ៉ាប់រងនេះ។ អ្នកលក់ ក៏ត្រូវឱ្យអ្នកផ្តល់សេវាធានារ៉ាប់រងបំណុលរបស់ខ្លួនបញ្ចូលឈ្មោះរបស់អ្នកទិញនៅលើបណ្ណសន្យារ៉ាប់រងជាឈ្មោះធានាបន្ថែមដែលផលប្រយោជន៍របស់អ្នកទិញអាចនឹងមានពាក់ព័ន្ធនឹងកិច្ចសន្យា។

## 15. សវនកម្ម

អ្នកលក់ យល់ព្រមរក្សាកំណត់ត្រាដែលគាំទ្រដល់ចំនួនទឹកប្រាក់ទាំងអស់ដែលបានចេញវិក្កយបត្រ នៅក្រោមកិច្ចសន្យានេះស្របតាមការអនុវត្តគណនេយ្យកិច្ចដែលទទួលយកបានជាទូទៅ។ អ្នកលក់ត្រូវផ្តល់កំណត់ត្រានោះដល់អ្នកទិញ ឬអ្នកតំណាងដែលកំណត់ដោយអ្នកនៅពេលវេលាសមស្របទាំងអស់រហូតដល់កាលបរិច្ឆេទផុតសុពលភាពបី (3) ឆ្នាំបន្ទាប់ពីកាលបរិច្ឆេទនៃការទូទាត់ចុងក្រោយសម្រាប់គោលបំណងនៃការធ្វើសវនកម្មកិច្ចសន្យា។ ក្នុងករណីដែលសវនកម្មកំណត់ថា អ្នកទិញបានទូទាត់លើសដល់អ្នកលក់ នោះអ្នកលក់ត្រូវទូទាត់ត្រលប់មកអ្នកទិញវិញនៅក្នុងរយៈពេលសាមសិប (30) ថ្ងៃបន្ទាប់ពីការទទួលសំណើជាលាយលក្ខណ៍អក្សរអំពីការទូទាត់ត្រលប់នូវចំនួនទឹកប្រាក់ដែលទូទាត់លើសនោះ។

## 16. សិទ្ធិកម្មសិទ្ធិបញ្ញា

16.1 អ្នកលក់សូមធ្វើការធានាថា ការលក់ ឬការប្រើប្រាស់ទំនិញណាមួយ នឹងមិនរំលោភបំពានលើប៉ាតង់ ពាណិជ្ជសញ្ញា ការរចនាដែលបានចុះបញ្ជី ឬសិទ្ធិកម្មសិទ្ធិបញ្ញាឧស្សាហកម្មផ្សេងទៀតនៅកម្ពុជា ឬនៅបរទេសមិនថាស្រដៀង ឬមិនស្រដៀងទៅនឹងកម្មសិទ្ធិបញ្ញាណាមួយខាងលើក្តី។

16.2 អ្នកលក់ត្រូវធានាសងចំពោះអ្នកទិញពីវិធានការ ការចំណាយ ការទាមទារសំណង ការទាមទារ ចំណាយនានា និងទំនួលខុសត្រូវទាំងអស់ដែលកើតចេញពី ឬបណ្តាលមកពីការរំលោភបំពានជាក់ស្តែង ឬដែលបានចោទប្រកាន់ដូចបានលើកឡើងនៅក្នុងប្រការ 16.1 ខាងលើ ហើយអ្នកលក់នឹងការពារសាច់ប្រាក់នានាដែលអាចនឹងលើកយកមកពាក់ព័ន្ធនឹងករណីនេះដោយចំណាយរបស់អ្នកលក់។ អ្នកលក់ក៏យល់ព្រមទូទាត់ចំពោះថ្លៃចំណាយនានានៃការការពារនេះ រួមទាំងថ្លៃចំណាយផ្លូវច្បាប់ និងបន្តយល់ព្រមទូទាត់ និងដកសាលក្រម ដីកាសម្រេច ឬដីកានានាដែលអាចនឹងជំរុញឱ្យមានការប្តឹងផ្តល់ វិធានការ ឬដំណើរការនីតិវិធីប្រឆាំងទៅលើអ្នកទិញសម្រាប់ការរំលោភបំពានដែលបានចោទប្រកាន់នោះ។ ប្រសិនបើអ្នកទិញត្រូវបានរារាំងពីការប្រើប្រាស់ទំនិញ ឬសេវាកម្មដែលបានផ្តល់ជូនខាងក្រោម នោះអ្នកលក់ត្រូវតែទិញយកមកវិញនូវទំនិញ/សេវាកម្មនោះពីអ្នកទិញវិញនៅតម្លៃដើម បូករួមជាមួយថ្លៃចំណាយដឹកជញ្ជូន ដំឡើង (ប្រសិនបើមាន) និងថ្លៃចំណាយផ្សេងទៀតទាំងអស់ពាក់ព័ន្ធនឹងការទិញនេះ។

16.3 ទំនិញមិនត្រូវផលិត ឬលក់ ឬឱ្យលក់ដោយអ្នកលក់ដោយបំពានលើសិទ្ធិណាមួយរបស់ភាគីទីបី និងជាពិសេស ដោយមិនគិតទៅលើភាពទូទៅនៃចំណុចខាងលើ សិទ្ធិប៉ាតង់ ពាណិជ្ជសញ្ញា ឬសិទ្ធិស្រដៀងគ្នា ឬកម្រៃ ការបញ្ជាំ ឬ ប្រាតិភោគបំណុលណាមួយ។

16.4 អ្នកលក់មិនត្រូវប្រើប្រាស់ស្លាកសញ្ញា រូបភាព រូបក្រាហ្វិក ពាណិជ្ជសញ្ញា ឬឈ្មោះពាណិជ្ជកម្មរបស់អ្នកទិញ និងធ្វើការយោងណាមួយទៅលើអ្នកទិញ (រួមមានជាអាទិ៍ ការយោងទៅលើអ្នកទិញជាអតិថិជនរបស់អ្នកលក់) នៅក្នុងសំណើទិញ សកម្មភាពផ្សព្វផ្សាយ សកម្មភាពទីផ្សារ ខិត្តប័ណ្ណ ឬឯកសារស្រដៀងគ្នាផ្សេងទៀតរបស់អ្នកទិញដោយមិនមានការអនុញ្ញាតជាមុនពីអ្នកទិញ។

16.5 លើកលែងតែព្រមព្រៀងគ្នាផ្សេងពីនេះដោយអ្នកទិញ សិទ្ធិអ្នកនិពន្ធ (និងកម្មសិទ្ធិបញ្ញាផ្សេងទៀត) កម្មសិទ្ធិ និងសិទ្ធិអាស្រ័យផលនៃវត្ថុដែលបានផ្តល់ជូន និងសម្ភារៈដែលបង្កើតបានជាផ្នែកនៃទំនិញ និង/ឬសេវាកម្មដែលបានព្រមព្រៀងសម្រាប់អ្នកទិញ ត្រូវតែជាកម្មសិទ្ធិរបស់អ្នកទិញ ហើយអ្នកទិញត្រូវមានសិទ្ធិប្រើប្រាស់វត្ថុដែលបានផ្តល់ជូន និងសម្ភារៈទាំងនោះតាមលក្ខណៈណាក៏បានតាមឆន្ទានុសិទ្ធិផ្តាច់មុខរបស់ខ្លួន។

## 17. ការធានាសង

ដល់កម្រិតវិសាលភាពពេញលេញដែលច្បាប់អនុញ្ញាត អ្នកលក់យល់ព្រមធានាសង និងលើកលែងអ្នកទិញ មន្ត្រី អភិបាល និយោជិត និងភ្នាក់ងាររបស់អ្នកទិញពី និងប្រឆាំងនឹងការទាមទារ ការប្តឹងផ្តល់ ការខូចខាត និងការខាតបង់ទាំងអស់ រួមមានថ្លៃ និងចំណាយលើមេធាវីសមស្រប ដែលកើតចេញពីការធ្វេសប្រហែស ការប្រព្រឹត្តខុសឆ្គង ឬការខកខាន ឬការបំពានខចែង និងលក្ខខណ្ឌណាមួយរបស់អ្នកលក់។

## 18. គោលនយោបាយស្តីពីសន្តិសុខព័ត៌មាន

អ្នកលក់ដែលប្រើប្រាស់ប្រព័ន្ធរបស់អ្នកទិញ ឬចូលប្រើប្រាស់ព័ត៌មានរបស់អ្នកទិញតាមប្រព័ន្ធអេឡិចត្រូនិក ឬប្រព័ន្ធផ្សេងៗ ត្រូវតែប្រកាន់ខ្ជាប់តាមគោលនយោបាយ និងនីតិវិធីទាំងអស់របស់អ្នកទិញ ដូចបានកំណត់នៅក្នុង គោលនយោបាយស្តីពីសន្តិសុខព័ត៌មានរបស់អ្នកទិញសម្រាប់អ្នកលក់ និងត្រូវធានាថា អ្នកលក់ទាំងអស់ និងអ្នកដែលធ្វើការឱ្យ ឬតាមរយៈអ្នកលក់ រួមទាំងនិយោជិត និងអ្នកម៉ៅការបន្តរបស់អ្នកលក់ អនុលោមតាមបញ្ញត្តិនេះ។

## 19. សាច់ញាតិជិត និងអតីតបុគ្គលិករបស់ធនាគារ អប៊ី.អេច.

អ្នកលក់ត្រូវខិតខំប្រឹងប្រែងអស់ពីសមត្ថភាពរបស់ខ្លួន ក្នុងការមិនផ្ទេរកិច្ចសន្យាទៅឱ្យនិយោជិតណាមួយរបស់អ្នកទិញ ឬនិយោជិតរបស់អ្នកម៉ៅការបន្ត ដែលជាសាច់ញាតិនៃបុគ្គលិកបច្ចុប្បន្នរបស់ធនាគារ អ.អេច.ប៊ី។ សម្រាប់គោលបំណងនៃប្រការនេះ ពាក្យថា "សាច់ញាតិ" គឺត្រូវបានកំណត់និយមន័យជា (រួមមានជាអាទិ៍ អ្នកដែលជាប់សាច់ញាត់ដោយការស៊ីកូន និង/ឬទំនាក់ទំនងដោយអាពាហ៍ពិពាហ៍)៖ ម្តាយ ឪពុក បងប្អូនស្រី បងប្អូនប្រុស កូនប្រុស កូនស្រី មីង ពូ ក្មួយស្រី និងក្មួយប្រុស។ ក្នុងករណីដែលអ្នកទិញ ឬអ្នកលក់រកឃើញថា និយោជិតណាម្នាក់របស់អ្នកលក់ ឬនិយោជិតរបស់អ្នកម៉ៅការបន្ត គឺជាសាច់ញាតិរបស់បុគ្គលិកបច្ចុប្បន្នរបស់ ធនាគារ អ.អេច.ប៊ី អ្នកទិញអាចណែនាំអ្នកលក់ឱ្យផ្លាស់ប្តូរ ឬឱ្យគេផ្លាស់ប្តូរនិយោជិតនោះ ដោយមិនមានការគិតថ្លៃចំណាយបន្ថែមលើអ្នកទិញ ជាមួយនឹងនិយោជិតដែលមានជំនាញស្មើគ្នា ហើយអ្នកលក់ត្រូវអនុលោមតាមការណែនាំនេះ។ អ្នកលក់ ក៏ត្រូវទូទាត់ជូនវិញដល់អ្នកទិញនូវថ្លៃចំណាយផ្ទាល់ជាក់ស្តែងណាមួយដែលកើតឡើងចំពោះអ្នកទិញបណ្តាលមកពីការបំពានលើប្រការនេះ។ អ្នកលក់ ត្រូវជូនដំណឹងដល់អ្នកទិញអំពីនិយោជិតរបស់អ្នកលក់ ឬនិយោជិតរបស់អ្នកម៉ៅការបន្ត ដែលអ្នកលក់/អ្នកម៉ៅការបន្តមានបំណងចាត់តាំងឱ្យផ្តល់សេវាកម្មនៅក្រោមលក្ខខណ្ឌនេះ ដែលជាអតីតបុគ្គលិករបស់ធនាគារ អ.អេច.ប៊ី និងត្រូវធានាថាអតីតបុគ្គលិករបស់ធនាគារ អ.អេច.ប៊ី នេះគឺមិនពាក់ព័ន្ធនឹងការរឹតត្បិតការងារណាមួយស្របតាមការងារពីមុនរបស់បុគ្គលិកនោះជាមួយនឹងធនាគារ អ.អេច.ប៊ី។

## 20. សុចរិតភាពនៃលទ្ធកម្ម

20.1 អ្នកលក់យល់ព្រមប្រកាន់ខ្ជាប់តាមបទដ្ឋានសមត្ថភាពក្រមសីលធម៌ និងសុចរិតភាពខ្ពស់បំផុតនៅក្នុងការអនុវត្តកិច្ចសន្យា ដោយគិតគូរត្រឹមត្រូវចំពោះលក្ខណៈ និងគោលបំណងរបស់អ្នកទិញក្នុងនាមជាអង្គភាពមួយ និងធានាថានិយោជិតដែលបានចាត់តាំងឱ្យអនុវត្តការងារណាមួយនឹងប្រព្រឹត្តស្របទៅនឹងបទដ្ឋាននោះ។

20.2 អ្នកលក់សូមអះអាង និងធានាថា អ្នកលក់អនុលោមតាម និងត្រូវបន្តអនុលោមតាមច្បាប់ពាក់ព័ន្ធ បញ្ញត្តិ វិធាន បទប្បញ្ញត្តិ និងសេចក្តីបង្គាប់តាមច្បាប់របស់អាជ្ញាធរសាធារណៈ នៃដែនយុត្តាធិការណាមួយ ដែលការងារនោះត្រូវអនុវត្តនៅក្រោមកិច្ចសន្យានេះ។

20.3 អ្នកលក់ទទួលស្គាល់ថា អ្នកលក់ដឹងអំពី ព្រមទាំងនឹងអនុលោមតាមគោលនយោបាយស្តីពីអ្នកលក់របស់អ្នកទិញ រួមមានជាអាទ៍ គោលនយោបាយពាក់ព័ន្ធនឹងទំនាស់ផលប្រយោជន៍ ការតៃបន្លំ និងអំពើពុករលួយ អំណោយ ការប្រតិបត្តិរបស់បុគ្គលិកនៃអ្នកម៉ៅការ ទំនួលខុសត្រូវរបស់អ្នកម៉ៅការ និងគោលនយោបាយប្រឆាំងការលាងសម្អាតប្រាក់ (តទៅនេះហៅរួមគ្នាថា "គោលនយោបាយស្តីពីសុចរិតភាពអ្នកលក់របស់អ្នកទិញ")។ អ្នកលក់ធានាថា អ្នកលក់ និងនិយោជិត អ្នកម៉ៅការបន្តរបស់អ្នកលក់ និងនិយោជិតរបស់អ្នកម៉ៅការបន្ត គឺអនុលោមតាមគោលនយោបាយសុចរិតភាពអ្នកលក់របស់អ្នកទិញ និងមិនបានចូលរួមនៅក្នុងអំពើដែលនឹងនាំឱ្យមានការផ្អាក ការដកចេញ ឬការរកឃើញថាមិនមានសិទ្ធិគ្រប់គ្រាន់។

20.4 អ្នកលក់ និងអ្នកម៉ៅការបន្តទាំងអស់ ត្រូវខិតខំប្រឹងប្រែងឱ្យបានសមស្រប ដើម្បីធានាថាប្រាក់ដែលបានទូទាត់ដល់អ្នកលក់ និងអ្នកម៉ៅការបន្តទាំងអស់ដោយ ធនាគារ អ.អេច.ប៊ី គឺមិនត្រូវបានប្រើប្រាស់ ដើម្បីផ្តល់ហិរញ្ញប្បទាន គាំទ្រ ឬប្រព្រឹត្តអំពើភេរវកម្មឡើយ។

20.5 អ្នកលក់ និងនិយោជិតរបស់អ្នកលក់ អ្នកម៉ៅការបន្ត និងនិយោជិតរបស់អ្នកម៉ៅការបន្ត ក្នុងអំឡុងពេលនៃលក្ខខណ្ឌនេះ ត្រូវតែចៀសវាងដាច់ខាតនូវសកម្មភាពនានាដែលអាចបង្កើតទំនាស់ផលប្រយោជន៍ពិតប្រាកដ ឬជាក់ស្តែងជាមួយនឹងភារកិច្ចរបស់ខ្លួនចំពោះអ្នកទិញនៅក្រោមលក្ខខណ្ឌនេះ។

20.6 អ្នកលក់ធានាថា មិនមានមន្ត្រីរបស់ធនាគារ អ.អេច.ប៊ី ឬសមាជិកណាម្នាក់ដែលបានទទួល ឬនឹងត្រូវបានអ្នកលក់ផ្តល់ជូននូវអំណោយ គុណប្រយោជន៍ ឬអត្ថប្រយោជន៍ដោយផ្ទាល់ ឬដោយប្រយោលដែលកើតចេញពីលក្ខខណ្ឌនេះ ឬរង្វាន់ឡើយ។

20.7 លាភការរបស់អ្នកលក់ ត្រូវតែបង្កើតជាលាភការផ្តាច់មុខពាក់ព័ន្ធនឹងលក្ខខណ្ឌនេះប៉ុណ្ណោះ។ អ្នកលក់មិនត្រូវទទួលយកដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួននូវកម្រៃជើងសារពាណិជ្ជកម្ម ការបញ្ចុះតម្លៃ ឬការទូទាត់ស្រដៀងគ្នាពាក់ព័ន្ធនឹងសកម្មភាពស្របតាមលក្ខខណ្ឌនេះ ឬនៅក្នុងការអនុវត្តកាតព្វកិច្ចនៅក្រោមកិច្ចសន្យានេះ ហើយអ្នកលក់ត្រូវប្រឹងប្រែងឱ្យអស់ពីសមត្ថភាពក្នុងការធានាឱ្យបានថា អ្នកម៉ៅការបន្ត និយោជិត ភ្នាក់ងារ និងអ្នកតំណាងណាមួយរបស់អ្នកលក់ និងអ្នកម៉ៅការបន្ត មិនទទួលលាភការបន្ថែមណាមួយឡើយ។ អ្នកលក់ត្រូវតែបញ្ចេញព័ត៌មានជាលាយលក្ខណ៍អក្សរតាមរយៈការផ្តល់ការជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អ្នកទិញ នូវកម្រៃ កម្រៃជើងសារ ប្រាក់បង្វិលមកវិញ និងការបញ្ចុះតម្លៃទាំងអស់ដែលបានទូទាត់ ឬទទួលពាក់ព័ន្ធនឹងកិច្ចសន្យា។

20.8 អ្នកលក់យល់ព្រមថា នៅក្នុងរយៈពេល 30 ថ្ងៃនៃការមានមូលដ្ឋានសមហេតុផលក្នុងការជឿថាអ្នកលក់ និយោជិត អ្នកម៉ៅការបន្តរបស់អ្នកលក់ ឬនិយោជិតរបស់អ្នកម៉ៅការបន្តបាន៖

(i) បំពានច្បាប់ពាក់ព័ន្ធ បញ្ញត្តិ បទបញ្ជា បទប្បញ្ញត្តិ និងសេចក្តីបង្គាប់ស្របច្បាប់ណាមួយរបស់អាជ្ញាធរសាធារណៈ នៅក្នុងការអនុវត្តកិច្ចសន្យា

(ii) បំពានគោលនយោបាយសុចរិតភាពអ្នកលក់របស់អ្នកទិញ

(iii) ចូលរួមនៅក្នុងអំពើដែលអាចនឹងនាំឱ្យមានការផ្អាក ការដកចេញ ឬការរកឃើញថាមិនមានសិទ្ធិគ្រប់គ្រាន់

(iv) ប្រើប្រាស់ប្រាក់ដែលទូទាត់ជូនដោយធនាគារ អ អេច ប៊ី ទៅឱ្យអ្នកលក់ ឬអ្នកម៉ៅការបន្តណាមួយ ដើម្បីផ្តល់ហិរញ្ញប្បទាន គាំទ្រ ឬប្រព្រឹត្តអំពើភេរវកម្ម ឬ

(v) ទំនាស់ផលប្រយោជន៍ជាក់ស្តែង អាចកើតឡើង ឬកើតមាន អ្នកលក់នឹងបញ្ចេញព័ត៌មានជូនជាលាយលក្ខណ៍អក្សរតាមរយៈការផ្តល់ការជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ធនាគារ អ អេច ប៊ី អំពីការបំពាន ការប្រព្រឹត្ត ការប្រើប្រាស់ប្រាក់ដែលហាមឃាត់ ឬទំនាស់ផលប្រយោជន៍នោះ។

20.9 អ្នកលក់យល់ព្រមថា អ្នកលក់នឹងមិនដោះលែង បន្ទាបបន្ថោក ផ្អាក គម្រាមកំហែង បៀតបៀន សងសឹកលើ ឬរើសអើងនិយោជិតណាមួយរបស់អ្នកលក់ក្នុងខថែង និងលក្ខខណ្ឌការងាររបស់និយោជិតនោះ ជាការសងសឹកទៅលើការបញ្ចេញព័ត៌មានរបស់និយោជិតនោះទៅកាន់អ្នកទិញ ឬអាជ្ញាធរសមស្របផ្សេងទៀត នូវព័ត៌មានពាក់ព័ន្ធនឹងការបំពានគោលនយោបាយសុចរិតភាពអ្នកលក់របស់អ្នកទិញ ឬការបំពានធ្ងន់ធ្ងរទៅលើច្បាប់ពាក់ព័ន្ធនឹងការផ្តល់ ឬការអនុវត្តកិច្ចសន្យា។

## 21. ប្រធានសក្តិ

ទោះបីជាបញ្ញត្តិណាមួយផ្សេងទៀតនៃលក្ខខណ្ឌទាំងនេះមានចែងយ៉ាងណាក៏ដោយ ក៏អ្នកទិញត្រូវតែមានសិទ្ធិផ្អាកការប្រគល់ទំនិញ និង/ឬសេវាកម្មណាមួយ និង/ឬលុបចោលប័ណ្ណបញ្ជាទិញ និង/ឬប័ណ្ណការងារណាមួយ និង/ឬបញ្ចប់កិច្ចសន្យាណាមួយសម្រាប់ទំនិញ និង/ឬសេវាកម្ម ប្រសិនបើដោយសារតែមូលហេតុដែលហួសពីសមត្ថភាពគ្រប់គ្រងសមហេតុផល (រួមមានជាអាទិ៍ អគ្គិភ័យ ការបំផ្ទុះ ទឹកជំនន់ សង្គ្រាម អាកាសធាតុ វិធានការឧស្សាហកម្ម កូដកម្ម ការបិទទ្វារមិនឱ្យចូល ការបញ្ឈប់ការងារ ការអន្តរាគមន៍របស់រដ្ឋាភិបាល ការរុះរើរោងចក្រ ឬគ្រឿងម៉ាស៊ីន) ដែលរារាំង ឬទប់ស្កាត់ពីការយក ឬលក់បន្ត ឬប្រើប្រាស់ផលិតផល និង/ឬសេវាកម្មនោះ ឬវឌ្ឍនភាពនៃការងារ/គម្រោងរបស់ខ្លួនដែលរងផលប៉ះពាល់ដោយសារតែអ្នកលក់មិនមានលទ្ធភាពផ្គត់ផ្គង់ទំនិញ និង/ឬសេវាកម្មដែលត្រូវការចាំបាច់សម្រាប់ការងារ/គម្រោង ដោយសារតែមូលហេតុដែលហួសពីសមត្ថភាពគ្រប់គ្រងសមហេតុផលរបស់អ្នកលក់ ហើយអ្នកទិញមិនត្រូវមានកាតព្វកិច្ចចំពោះអ្នកលក់ឡើយចំពោះការខាតបង់ដែលទទួលរង ឬកើតឡើងដែលជាលទ្ធផលនៃការផ្អាក ការលុបចោល ឬការបញ្ចប់នេះដែលមិនត្រូវប៉ះពាល់ដល់សិទ្ធិ និងទំនួលខុសត្រូវរបស់គូភាគីដែលបូកបង្គរនៅពេលនោះទេ។

## 22. ការរក្សាព័ត៌មានសម្ងាត់ និងការការពារទិន្នន័យផ្ទាល់ខ្លួន

អ្នកលក់មិនត្រូវប្រកាស ឬបញ្ចេញព័ត៌មានអំពីការព្រមព្រៀងកិច្ចសន្យារវាងអ្នកលក់ និងអ្នកទិញ ឬចំណុចនានានៃកិច្ចព្រមព្រៀងនោះទេ លើកលែងតែបានព្រមព្រៀងគ្នាជាពិសេសដោយអ្នកទិញជាលាយលក្ខណ៍អក្សរ ឬតាមការតម្រូវដោយច្បាប់។ ការប្រកាស ឬការបញ្ចេញព័ត៌មានដោយអ្នកលក់ ក្នុងករណីណាក៏ដោយ ត្រូវតែធ្វើឡើងតែបន្ទាប់ពីការពិគ្រោះយោបល់ជាមុនជាមួយនឹងអ្នកទិញ និងទទួលបានការអនុម័តពីអ្នកទិញចំពោះខ្លឹមសារនៃការប្រកាស ឬការបញ្ចេញព័ត៌មាននោះ។ ប្រសិនបើ

មានកាតព្វកិច្ចនានាកើតចេញពីលក្ខខណ្ឌតម្រូវអនុលោមភាពចំពោះច្បាប់ស្តីពីការការពារទិន្នន័យផ្ទាល់ខ្លួន ឆ្នាំ2010 ចំពោះព័ត៌មានអ្នកទិញបានផ្តល់ជូន អ្នកទិញយល់ព្រមគោរពតាមខចែង និងលក្ខខណ្ឌដូចមានចែងនៅក្នុង**ឯកសារភ្ជាប់ 1** នៃកិច្ចសន្យានេះ។

## 23. ការបញ្ចប់កិច្ចសន្យា

អ្នកទិញត្រូវមានសិទ្ធិបញ្ចប់លក្ខខណ្ឌ ឬកិច្ចសន្យាណាមួយដែលបានធ្វើឡើងខាងក្រោម ដោយជូនដំណឹងមុនជាលាយលក្ខណ៍អក្សររយៈពេល 7 ថ្ងៃដល់អ្នកលក់ ប្រសិនបើ៖-

(ក) ប្រសិនបើអ្នកលក់ខកខានមិនប្រគល់ទំនិញ និង/ឬសេវាកម្មស្របតាមខចែង និងលក្ខខណ្ឌនៃលក្ខខណ្ឌនេះ

(ខ) អ្នកលក់ប្រព្រឹត្តបំពានលើលក្ខខណ្ឌទាំងនេះ ឬបញ្ញត្តិណាមួយផ្សេងទៀតនៃកិច្ចសន្យានានា និងនៅក្នុងករណីដែលការបំពានដែលមានលទ្ធភាពអាចដោះស្រាយបាន ប៉ុន្តែមិនអាចដោះស្រាយទៅបានក្នុងរយៈពេលប្រាំពីរ (7) ថ្ងៃបន្ទាប់ពីការជូនដំណឹងជាលាយលក្ខណ៍អក្សរ ឬ

(គ) អ្នកលក់ប្រព្រឹត្តសកម្មភាពណាមួយនៃការក្ស័យធន ឬមានអ្នកទទួល ឬអ្នកទទួលរដ្ឋបាលដែលបានចាត់តាំងដែលត្រូវទទួលទ្រព្យសម្បត្តិរបស់ខ្លួនទាំងអស់ ឬមួយផ្នែក ឬប្រសិនបើមានដីកា ឬដំណោះស្រាយដែលបានសម្រេចសម្រាប់ការជម្រះបញ្ជីទ្រព្យសម្បត្តិទាំងអស់ ឬដោយផ្នែករបស់អ្នកលក់ ឬប្រសិនបើដីកាដែលបានធ្វើឡើង ឬសេចក្តីសម្រេចដែលបានអនុម័តសម្រាប់ការជម្រះបញ្ជីអ្នកលក់ ឬបិទអាជីវកម្មរបស់អ្នកលក់ ឬអ្នកលក់គឺជាកម្មវត្ថុនៃព្រឹត្តការណ៍ដូចគ្នា ឬដំណើរការនីតិវិធីនៅក្រោមច្បាប់នៃដែនយុត្តាធិការណាមួយ ឬ

(ឃ) អ្នកលក់មានស្ថានភាពថវិការបស់ភាគទុនិកអវិជ្ជមាន ដែលតាមគំនិតរបស់ធនាគារ អ អេច ប៊ី អាច ឬអាចនឹងប៉ះពាល់យ៉ាងធ្ងន់ធ្ងរ និងអវិជ្ជមានដល់សមត្ថភាពរបស់អ្នកលក់ក្នុងការអនុវត្តសេវាកម្ម ឬ

(ង) ក្នុងករណីមានការកាន់កាប់ភាគហ៊ុនបោះឆ្នោត ឬការទិញអាជីវកម្ម ទ្រព្យសកម្ម និង/ឬទ្រព្យអកម្មទាំងអស់ ឬសំខាន់ៗទាំងអស់របស់អ្នកទិញ ឬក្រុមហ៊ុនមេរបស់ខ្លួន ឬវិធានការណាមួយដែលត្រូវបានអនុវត្តដោយអ្នកទិញ ឬក្រុមហ៊ុនមេរបស់ខ្លួនពាក់ព័ន្ធនឹងភាគហ៊ុនបោះឆ្នោត ឬអាជីវកម្ម ទ្រព្យសកម្ម និង/ឬទ្រព្យអកម្មរបស់ក្រុមហ៊ុនមួយទៀត ឬករណីផ្សេងទៀតដែលមានឥទ្ធិពលស្រដៀងគ្នា ដែលនាំឱ្យមានការផ្លាស់ប្តូរការគ្រប់គ្រងរបស់អ្នកទិញ ឬក្រុមហ៊ុនមេរបស់ខ្លួន (តទៅនេះហៅកាត់ថា "**ព្រឹត្តិការណ៍**")។ កាលបរិច្ឆេទមានប្រសិទ្ធភាពដែលព្រឹត្តិការណ៍នោះត្រូវបានចាត់ទុកថាបានកើតឡើង គឺមានដូចខាងក្រោម៖-

(i) ក្នុងករណីមានការកាន់កាប់ជំនួសនៅកាលបរិច្ឆេទបិទការទទួលយកការកាន់កាប់ជំនួសនោះ

(ii) ក្នុងករណីនៃការទិញ កាលបរិច្ឆេទបញ្ចប់នៃកិច្ចព្រមព្រៀងទិញពាក់ព័ន្ធ ឬ

(ii) ក្នុងករណីមានឥទ្ធិពលស្រដៀងគ្នាផ្សេងទៀត កាលបរិច្ឆេទដែលប្រតិបត្តិការមានឥទ្ធិពលទៅលើការផ្លាស់ប្តូរការគ្រប់គ្រង គឺត្រូវបានចាត់ទុកថាបានបញ្ចប់។

(ច) ដោយសារតែច្បាប់ថ្មី ឬការផ្លាស់ប្តូរទៅលើច្បាប់ គោលការណ៍ណែនាំ ឬសេចក្តីណែនាំពីអាជ្ញាធរនិយ័តកម្មដែលចងភ្ជាប់កាតព្វកិច្ចលើធនាគារ អ.អេច.ប៊ី ដែលធ្វើឱ្យការបន្តអនុវត្តលក្ខខណ្ឌនេះមិនមានសុពលភាព ឬមិនអាចអនុវត្តទៅបាន។

## 24. ការបញ្ចប់កិច្ចសន្យាដើម្បីភាពងាយស្រួល

ទោះបីជាប្រការផ្សេងៗដែលផ្ទុយនឹងប្រការដែលមាននៅក្នុងកិច្ចសន្យានេះក៏ដោយ អ្នកទិញអាចបញ្ចប់លក្ខខណ្ឌនេះដោយមិនចាំបាច់ផ្តល់មូលហេតុណាមួយឡើយ ដោយផ្តល់ការជូនដំណឹងមុនជាលាយលក្ខណ៍អក្សរសាមសិប (30) ថ្ងៃដល់អ្នកលក់។

## 25. ការផ្ទេរ

អ្នកលក់មិនត្រូវផ្ទេរកិច្ចសន្យា ឬប្រាក់ណាមួយដែលត្រូវទូទាត់ ឬក្លាយជាត្រូវទូទាត់ដោយមិនមានការអនុញ្ញាតជាមុនជាលាយលក្ខណ៍អក្សរដោយអ្នកទិញដោយ។ អ្នកទិញ តាមជម្រើសទាំងស្រុងរបស់ខ្លួន និងដោយមិនចាំបាច់មានាការអណុញ្ញាតពីអ្នកលក់ អាចផ្ទេរកិច្ចសន្យានេះ និងការងារកិច្ចសន្យាណាមួយដែលទទួលបាននៅខាងក្រោមទៅឱ្យសមាជិកណាមួយនៃធនាគារ អ.អេច.ប៊ី។

## 26. គោលនយោបាយមិនអនុញ្ញាតឱ្យផ្តល់អំណោយ

អ្នកលក់ អ្នកផ្គត់ផ្គង់ ឬបុគ្គល ឬអង្គភាពណាមួយផ្សេងទៀត មិនត្រូវផ្តល់អំណោយប្រភេទណាមួយដល់និយោជិតរបស់**ធនាគារ អ.អេច.ប៊ី** មិនថាជាអំណោយជាក់ស្តែង ឬនឹងផ្តល់ជូន ដោយមិនគិតអំពីតម្លៃឡើយ។

## 27. ការហាមឃាត់លើការប្រើប្រាស់ឈ្មោះ និងស្លាកសញ្ញា

អ្នកលក់មិនត្រូវប្រើប្រាស់ស្លាកសញ្ញា រូបភាព រូបក្រាហ្វិក ពាណិជ្ជសញ្ញា ឬឈ្មោះពាណិជ្ជកម្មរបស់អ្នកទិញ និងធ្វើការយោងណាមួយទៅលើអ្នកទិញ (រួមមានជាអាទិ៍ ការយោងទៅលើអ្នកទិញជាអតិថិជនរបស់អ្នកលក់) នៅក្នុងសំណើទិញ សកម្មភាពផ្សព្វផ្សាយ សកម្មភាពទីផ្សារ ខិត្តប័ណ្ណ ឬឯកសារស្រដៀងគ្នាផ្សេងទៀតរបស់អ្នកលក់ដោយមិនមានការអនុញ្ញាតជាមុនពីអ្នកទិញ។

## 28. ពន្ធ

28.1 ក្នុងករណីដែលពន្ធត្រូវបានដាក់បន្ទុកដោយអាជ្ញាធរពាក់ព័ន្ធនៅពេលណាមួយ និងពីពេលមួយទៅពេលមួយដែលអនុវត្តចំពោះការផ្គត់ផ្គង់ទំនិញ ឬសេវាកម្មណាមួយដែលធ្វើឡើងដោយអ្នកលក់នៅក្រោមកិច្ចព្រមព្រៀងនេះ (តទៅនេះហៅកាត់ថា "ពន្ធ") អ្នកលក់មានសិទ្ធិគិតពន្ធទៅលើការទូទាត់នៃការផ្គត់ផ្គង់ទំនិញ និងសេវាកម្មនោះ។

28.2 ការព្រមព្រៀងពន្ធនានាទាំងអស់ ត្រូវតែស្របតាមច្បាប់ និងបទប្បញ្ញត្តិអាទិភាព។ អ្នកទិញរក្សាសិទ្ធិក្នុងការកែប្រែប្រការ 28 នេះ ប្រសិនបើមានការផ្លាស់ប្តូរណាមួយទៅលើច្បាប់ និងបទប្បញ្ញត្តិនោះ។

**29. រយៈពេលទូទាត់**

លុះត្រាណាតែមានចែងផ្សេងពីនេះនៅក្នុងប័ណ្ណបញ្ជាទិញណាមួយដែលចេញដោយអ្នកទិញ រយៈពេលទូទាត់ត្រូវមានរយៈពេលសាមសិប (30) ថ្ងៃគិតចាប់ពីកាលបរិច្ឆេទទទួលវិក្កយបត្រ។

**30. ច្បាប់គ្រប់គ្រង និងដែនយុត្តាធិការ**

លក្ខខណ្ឌនេះ ត្រូវគ្រប់គ្រងដោយច្បាប់នៃប្រទេសកម្ពុជា ហើយគូភាគីត្រូវដាក់ជូនដល់ដែនយុត្តាធិការនៃតុលាការរបស់ប្រទេសកម្ពុជា នូវបញ្ហានានាដែលពាក់ព័ន្ធនឹងកាតព្វកិច្ច និងទំនួលខុសត្រូវនានារបស់គូភាគីនៅក្រោមលក្ខខណ្ឌនេះ។

## ឯកសារភ្ជាប់ 1

## ការការពារទិន្នន័យផ្ទាល់ខ្លួន

1 អ្នកលក់ទទួលខុសត្រូវអនុលោមឱ្យបានពេញលេញតាមបញ្ញត្តិនៃច្បាប់ស្តីពីការការពារទិន្នន័យផ្ទាល់ខ្លួន ឆ្នាំ2010 (តទៅនេះហៅកាត់ថា "ច្បាប់") ព្រមទាំងច្បាប់ បទប្បញ្ញត្តិ និងបទដ្ឋានឧស្សាហកម្មផ្សេងៗដែលពាក់ព័ន្ធនឹងឯកជនភាព ការរក្សាព័ត៌មានសម្ងាត់ ឬសន្តិសុខនៃទិន្នន័យផ្ទាល់ខ្លួន (ហៅរួមគ្នាថា "ច្បាប់ស្តីពីឯកជនភាព")។

2 អ្នកលក់ត្រូវតែដំណើរការទិន្នន័យផ្ទាល់ខ្លួនតែនៅពេលជំនួសឱ្យ និងសម្រាប់ផលប្រយោជន៍របស់អ្នកទិញប៉ុណ្ណោះ ដល់ត្រឹមតែវិសាលភាពដែលចាំបាច់សម្រាប់គោលបំណងនៃការដំណើរការទិន្នន័យផ្ទាល់ខ្លួនពាក់ព័ន្ធនឹងលក្ខខណ្ឌនេះ និងការអនុវត្តកាតព្វកិច្ចរបស់ខ្លួនស្របតាមលក្ខខណ្ឌនេះ និងយោងតាមសេចក្តីណែនាំជាលាយលក្ខណ៍អក្សររបស់អ្នកទិញប៉ុណ្ណោះ។

3 អ្នកទិញត្រូវមានសិទ្ធិអំណាចផ្តាច់មុខក្នុងការកំណត់គោលបំណង និងមធ្យោបាយនៃការដំណើរការទិន្នន័យផ្ទាល់ខ្លួន និងរក្សាសិទ្ធិក្នុងការកែប្រែគោលបំណង និងមធ្យោបាយនោះពីពេលមួយទៅពេលមួយ។

4 អ្នកលក់ និងនិយោជិតរបស់ខ្លួន ត្រូវប្រកាន់ខ្ជាប់នូវការសម្ងាត់ពាក់ព័ន្ធនឹងទិន្នន័យផ្ទាល់ខ្លួនណាមួយ និងទាំងអស់។

5 អ្នកលក់ត្រូវធានាថាការចូលប្រើប្រាស់ទិន្នន័យផ្ទាល់ខ្លួន គឺកម្រិតត្រឹម៖

(ក) និយោជិតដែលចាំបាច់ត្រូវការចូលប្រើប្រាស់ទិន្នន័យផ្ទាល់ខ្លួន ដើម្បីបំពេញកាតព្វកិច្ចរបស់អ្នកលក់នៅក្រោមលក្ខខណ្ឌនេះ និង

(ខ) ក្នុងករណីដែលមានការចូលប្រើប្រាស់ដោយនិយោជិតណាម្នាក់ ផ្នែកនោះ ឬផ្នែកនានានៃទិន្នន័យផ្ទាល់ខ្លួន គឺត្រូវតែចាំបាច់ជាខ្លាំងសម្រាប់ការអនុវត្តភារកិច្ចរបស់និយោជិតនោះ។

6 អ្នកលក់ត្រូវធានាថា និយោជិតទាំងអស់៖

(ក) ទទួលបានព័ត៌មានអំពីលក្ខណៈសម្ងាត់នៃទិន្នន័យផ្ទាល់ខ្លួន

(ខ) បានទទួលការបណ្តុះបណ្តាលអំពីច្បាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងទិន្នន័យផ្ទាល់ខ្លួន និង

(គ) ដឹងអំពីភារកិច្ចរបស់អ្នកលក់ ព្រមទាំងភារកិច្ច និងកាតព្វកិច្ចរបស់ពួកគេនៅក្រោមច្បាប់ និងលក្ខខណ្ឌនេះ

7 ក្នុងករណីដែលអ្នកទិញចែករំលែក ផ្ទេរ បញ្ចេញ ឬផ្តល់សិទ្ធិចូលប្រើប្រាស់ទិន្នន័យផ្ទាល់ខ្លួនដល់អ្នកលក់ អ្នកលក់ត្រូវ៖-

(ក) ដាក់ចេញនូវការការពារសន្តិសុខសមស្រប ដើម្បីធានាបាននូវអនុលោមភាពតាមច្បាប់ស្តីពីឯកជនភាព រួមទាំងការអនុវត្តការការពារសន្តិសុខរដ្ឋបាល រូបវន្ត និងបច្ចេកទេស ដើម្បីការពារទិន្នន័យផ្ទាល់ខ្លួនដោយសមហេតុផល និងសមស្របដែលអាចបញ្ចេញដោយអ្នកទិញ ("**ទិន្នន័យរបស់អ្នកទិញ**")

(ខ) ដំណើរការទិន្នន័យរបស់អ្នកទិញសម្រាប់តែគោលបំណងពាក់ព័ន្ធនឹងសេវាកម្មប៉ុណ្ណោះ និងត្រូវអនុលោមឱ្យបានតឹងរ៉ឹងតាមសេចក្តីណែនាំទាំងអស់ដែលអ្នកទិញផ្តល់ជូនពាក់ព័ន្ធនឹងទិន្នន័យនោះ និង

(គ) រារាំងពីការបញ្ចេញទិន្នន័យណាមួយរបស់អ្នកទិញទៅឱ្យភាគីទីបីណាមួយ ឬផ្ទេរទិន្នន័យណាមួយរបស់អ្នកទិញនៅក្រៅប្រទេសកម្ពុជា ដោយមិនមានការអនុញ្ញាតជាមុនពីអ្នកទិញឡើយ។

8 ក្នុងករណីដែលអ្នកលក់ទទួលបានការអនុញ្ញាតឱ្យបញ្ចេញទិន្នន័យរបស់អ្នកទិញទៅកាន់ភាគីទីបីណាមួយ ឬអ្នកម៉ៅការក្នុងគោលបំណងដំណើរការទិន្នន័យរបស់អ្នកទិញពាក់ព័ន្ធនឹងលក្ខខណ្ឌនេះ អ្នកលក់ត្រូវតែចុះកិច្ចព្រមព្រៀងជាមួយភាគីទីបីនីមួយៗដែលដាក់បន្ទុកកាតព្វកិច្ចលើភាគីទីបី ដែលមានសារៈសំខាន់ស្រដៀងគ្នាទៅនឹងកាតព្វកិច្ចដែលដាក់បន្ទុកលើអ្នកលក់នៅក្រោមលក្ខខណ្ឌនេះ។

9 អ្នកលក់ត្រូវសហការជាមួយអ្នកទិញ ប្រសិនបើមានបុគ្គលស្នើសុំចូលប្រើប្រាស់ទិន្នន័យរបស់បុគ្គលនោះសម្រាប់គោលបំណងណាមួយ។

10 អ្នកលក់ត្រូវរក្សាការការពារសន្តិសុខសមហេតុផល និងវិធានការសន្តិសុខផ្សេងៗទៀតដែលរចនាឡើងដើម្បី (i) ធានាសន្តិសុខ និងការសម្ងាត់នៃទិន្នន័យផ្ទាល់ខ្លួន (ii) ការពារពីការគម្រាមកំហែង ឬគ្រោះថ្នាក់ដែលបានប៉ាន់ស្មានចំពោះសន្តិសុខ និងសុចរិតភាពនៃទិន្នន័យផ្ទាល់ខ្លួន និង (iii) ការពារពីការដំណើរការ ការបាត់បង់ ការប្រើប្រាស់ ការបញ្ចេញ ឬការទិញ ឬការចូលប្រើប្រាស់ទិន្នន័យផ្ទាល់ខ្លួនមិនមានការអនុញ្ញាតជាក់ស្តែង ឬសង្ស័យ (តទៅនេះហៅថា "គ្រោះថ្នាក់សន្តិសុខទិន្នន័យ")។

11 អ្នកលក់ត្រូវជូនដំណឹងភ្លាមៗដល់អ្នកទិញជាលាយលក្ខណ៍អក្សរអំពីគ្រោះថ្នាក់សន្តិសុខទិន្នន័យដែលអ្នកលក់បានដឹង ប៉ុន្តែមិនត្រូវពន្យារពេលយូរជាង 24 ម៉ោងបន្ទាប់ពីអ្នកលក់បានដឹងអំពីគ្រោះថ្នាក់សន្តិសុខទិន្នន័យនេះ។ ការជូនដំណឹងនេះ ត្រូវតែសង្ខេបដោយមានព័ត៌មានលម្អិតសមហេតុផលអំពីឥទ្ធិពលលើអ្នកទិញ ប្រសិនបើបានដឹង អំពីគ្រោះថ្នាក់សន្តិសុខទិន្នន័យ និងវិធានការកែតម្រូវដែលបានអនុវត្ត ឬនឹងត្រូវអនុវត្តដោយអ្នកលក់។ អ្នកលក់ ត្រូវចាត់វិធានការកែតម្រូវចាំបាច់ និងមានការណែនាំទាំងអស់ភ្លាមៗ និងត្រូវតែសហការឱ្យបានពេញលេញជាមួយអ្នកទិញនៅគ្រប់កិច្ចខិតខំប្រឹងប្រែងសមហេតុផល និងស្របច្បាប់ទាំងអស់ ដើម្បីទប់ស្កាត់ កាត់បន្ថយ ឬកែតម្រូវគ្រោះថ្នាក់សន្តិសុខទិន្នន័យនោះ។ ខ្លឹមសារនៃឯកសារ ការប្រាស្រ័យទាក់ទង ការជូនដំណឹង សេចក្តីប្រកាសសារព័ត៌មាន ឬរបាយការណ៍ពាក់ព័ន្ធនឹងគ្រោះថ្នាក់សន្តិសុខទិន្នន័យ ត្រូវតែអនុម័តដោយអ្នកទិញនៅមុនពេលការចុះផ្សាយ ឬការផ្សព្វផ្សាយ។

12 ភ្លាមៗបន្ទាប់ពីផុតសុពលភាព ឬការបញ្ចប់លក្ខខណ្ឌនេះមុនកំណត់ ឬនៅពេលណាមួយតាមសំណើរបស់អ្នកទិញ អ្នកលក់ត្រូវប្រគល់មកឱ្យអ្នកទិញ ឬតំណាងរបស់អ្នកទិញវិញ ឬតាមសំណើរបស់អ្នកទិញ បំផ្លាញ ឬធ្វើយ៉ាងណាមិនអាចឱ្យអានបាន ឬមិនអាចបកប្រែបានយ៉ាងមានសុវត្ថិភាព (ដែលការសម្រេចចិត្តនេះ ត្រូវតែផ្អែកទាំងស្រុងលើសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សររបស់អ្នកទិញ) នូវសំណៅដើម និងសំណៅថតចម្លងទាំងអស់នៅក្នុងឧបករណ៍ផ្ទុកទិន្នន័យផ្ទាល់ខ្លួនទាំងអស់នៅក្នុងកម្មសិទ្ធិ ការកាន់កាប់ ឬការគ្រប់គ្រងរបស់អ្នកលក់។ ក្នុងករណីដែលច្បាប់ពាក់ព័ន្ធមិនអនុញ្ញាតឱ្យអ្នកលក់អនុលោមតាមការប្រគល់ ឬការបំផ្លាញទិន្នន័យផ្ទាល់ខ្លួន អ្នកលក់ធានាថា អ្នកលក់ត្រូវធានាបាននូវការរក្សាការសម្ងាត់នៃទិន្នន័យផ្ទាល់ខ្លួន និងមិនត្រូវប្រើប្រាស់ ឬបញ្ចេញទិន្នន័យផ្ទាល់ខ្លួនណាមួយបន្ទាប់ពីការបញ្ចប់លក្ខខណ្ឌនេះឡើយ។

13 អ្នកលក់ត្រូវផ្តល់ជូនអ្នកទិញនូវសំណៅថតចម្លងនៃទិន្នន័យផ្ទាល់ខ្លួនទាំងអស់ដែលខ្លួនកាន់កាប់នៅក្នុងទម្រង់ និងនៅក្នុងឧបករណ៍ផ្ទុកដែលបញ្ជាក់យ៉ាងសមហេតុផលដោយអ្នកទិញនៅពេលអ្នកទិញស្នើសុំ។

14 អ្នកទិញត្រូវមានសិទ្ធិតាមដានត្រួតពិនិត្យអនុលោមភាពរបស់អ្នកលក់តាមខចែងនៃលក្ខខណ្ឌនេះ។ ក្នុងអំឡុងម៉ោងធ្វើការធម្មតា និងដោយមិនចាំបាច់មានការជូនដំណឹងជាមុន អ្នកទិញ ឬអ្នកតំណាងរបស់អ្នកទិញអាចត្រួតពិនិត្យហេដ្ឋារចនាសម្ព័ន្ធ បរិវេណ កំណត់ត្រា និងព័ត៌មាន ឬឯកសារនានារបស់អ្នកលក់ដែលស្ថិតក្រោមកម្មសិទ្ធិ ការកាន់កាប់ ឬការគ្រប់គ្រងរបស់អ្នកលក់ដែលពាក់ព័ន្ធទៅនឹងកាតព្វកិច្ចរបស់អ្នកលក់នៅក្រោមលក្ខខណ្ឌនេះ។ ការត្រួតពិនិត្យដែលអនុវត្តស្របតាមប្រការនេះមិនត្រូវរារាំងដោយមិនសមហេតុផលទៅនឹងប្រតិបត្តិការអាជីវកម្មជាធម្មតារបស់អ្នកលក់ឡើយ។ អ្នកលក់ត្រូវសហការឱ្យបានពេញលេញជាមួយនឹងការត្រួតពិនិត្យដែលផ្តួចផ្តើមដោយអ្នកទិញ។

15 អ្នកលក់ត្រូវដោះស្រាយឱ្យបានទាន់ពេលវេលា និងសមស្របចំពោះសំណួរនានាពីអ្នកទិញពាក់ព័ន្ធនឹងការដំណើរការទិន្នន័យផ្ទាល់ខ្លួនដែលទាក់ទងនឹង ឬមានសារៈសំខាន់ទៅនឹងការអនុវត្តលក្ខខណ្ឌនេះ។

16 អ្នកលក់យល់ព្រមជូនដំណឹងភ្លាមៗដល់អ្នកទិញក្នុងករណីមានការទាមទារ ការជូនដំណឹង ការប្រាស្រ័យទាក់ទង ឬបណ្តឹងតវ៉ាដែលពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោលទៅនឹងការដំណើរការទិន្នន័យផ្ទាល់ខ្លួន និង/ឬក្នុងករណីនៃការមិនអនុលោមតាមច្បាប់ស្តីពីឯកជនភាព និងគោលការណ៍ការពារទិន្នន័យដែលមានចែងនៅក្នុងច្បាប់ ដែលប្រព្រឹត្តដោយភាគីណាមួយ មិនថារកឃើញដោយអ្នកលក់ ឬបង្កើតបានជាកម្មវត្ថុនៃការស៊ើបអង្កេត និង/ឬការចាត់វិធានការដោយអាជ្ញាធរពាក់ព័ន្ធឡើយ។ អ្នកលក់ត្រូវផ្តល់ជូនអ្នកទិញនូវការសហការ និងជំនួយពេញលេញពាក់ព័ន្ធនឹងការទាមទារ ការជូនដំណឹង ការប្រាស្រ័យទាក់ទង ឬបណ្តឹងតវ៉ានោះ។

17 អ្នកលក់ត្រូវជូនដំណឹងដល់អ្នកទិញភ្លាមៗជាលាយលក្ខណ៍អក្សរអំពីដីកាកោះហៅ ឬដីកាតុលាការ ឬដីការដ្ឋបាលចេញដោយអាជ្ញាធររដ្ឋាភិបាល ឬដំណើរការនីតិវិធីដែលទាមទារការចូលប្រើប្រាស់ ឬការបញ្ចេញទិន្នន័យផ្ទាល់ខ្លួន។ អ្នកទិញត្រូវមានសិទ្ធិការពារវិធានការនេះជំនួសមុខ និងតាងនាមឱ្យអ្នកលក់។ អ្នកទិញអាចស្នើសុំដីកាការពារបាន ប្រសិនបើខ្លួនជ្រើសរើសធ្វើដូច្នោះ។ អ្នកលក់ត្រូវសហការដោយសមហេតុផលជាមួយនឹងអ្នកទិញនៅក្នុងការការពារនោះ។

18 អ្នកមៅការយល់ព្រមធានាសង និងលើកលែងអ្នកទិញ និងមន្ត្រី និយោជិត អភិបាល និងភ្នាក់ងាររបស់អ្នកទិញពី និងតាមជម្រើសរបស់អ្នកទិញការពារពីការទាមទារ ការខាតបង់ បំណុល ថ្លៃដើម និងថ្លៃចំណាយណាមួយ ឬទាំងអស់ រួមទាំងការទាមទាររបស់ភាគីទីបី ថ្លៃសេវាមេធាវីសមស្រប ថ្លៃសេវាពិគ្រោះយោបល់ និងប្រាក់ប្រដាប់ក្តី (ហៅរួមគ្នាថា "**ការទាមទារ**") ដល់កម្រិតវិសាលភាពដែលការទាមទារនោះកើតចេញពី ឬអាចនឹងរួមចំណែកតាមមធ្យោបាយណាមួយដល់ (i) ការបំពានណាមួយលើលក្ខខណ្ឌនេះ (ii) ការធ្វេសប្រហែសទាំងស្រុង ចេតនាមិនល្អ ឬការប្រព្រឹត្តដោយចេតនា ឬដោយគ្រោងទុករបស់អ្នកលក់ ឬនិយោជិតរបស់អ្នកលក់ពាក់ព័ន្ធនឹងកាតព្វកិច្ចដែលមានចែងនៅក្នុងលក្ខខណ្ឌនេះ (iii) អ្នកលក់ប្រើប្រាស់សេវាដែលផ្តល់ជូនដោយភាគីទីបីពាក់ព័ន្ធ ឬជាប់ទាក់ទងនឹងការអនុវត្តរបស់អ្នកលក់នៅក្រោមលក្ខខណ្ឌនេះ ឬ (iv) គ្រោះថ្នាក់សន្តិសុខទិន្នន័យណាមួយដែលពាក់ព័ន្ធនឹងទិន្នន័យផ្ទាល់ខ្លួននៅក្រោមកម្មសិទ្ធិ ការកាន់កាប់ ឬការគ្រប់គ្រងរបស់អ្នកលក់ ឬដែលស្ថិតក្រោមការទទួលខុសត្រូវរបស់អ្នកលក់។

19 អ្នកលក់យល់ព្រមថា ការដំណើរការទិន្នន័យផ្ទាល់ខ្លួនណាមួយដែលបំពានលើលក្ខខណ្ឌនេះ សេចក្តីណែនាំរបស់អ្នកទិញ ឬច្បាប់ស្តីពីឯកជនភាពពាក់ព័ន្ធ ឬគ្រោះថ្នាក់សន្តិសុខទិន្នន័យណាមួយ ដែលអាចបង្កឱ្យមានគ្រោះថ្នាក់ភ្លាមៗ ឬមិនអាចជួសជុលបានចំពោះអ្នកទិញដែលចំពោះគ្រោះថ្នាក់នេះ ការសងការខូចខាតជាហិរញ្ញវត្ថុអាចនឹងមិនបង្កើតជាឧបាស្រ័យគ្រប់គ្រាន់នោះទេ។ ដូច្នេះ អ្នកលក់យល់ព្រមថា អ្នកទិញអាចទទួលបានការអនុវត្តជាក់លាក់ និងការបង្គាប់ ឬការបន្ធូរបន្ថយដោយសមធម៌ផ្សេងៗចំពោះការបំពាន ឬគ្រោះថ្នាក់ណាមួយ បន្ថែមពីលើឧបាស្រ័យរបស់ខ្លួននៅតុលាការ ដោយមិនមានភស្តុតាង

បញ្ជាក់អំពីការខូចខាតជាក់ស្តែង។ អ្នកលក់យល់ព្រមលះបង់សិទ្ធិចំពោះលក្ខខណ្ឌតម្រូវណាមួយសម្រាប់ការរក្សា ឬការផ្សព្វផ្សាយសញ្ញាបណ្ណណាមួយពាក់ព័ន្ធនឹងឧបាស្រ័យនេះ។

20 កាតព្វកិច្ចរបស់អ្នកលក់នៅក្រោមលក្ខខណ្ឌនេះ ត្រូវបន្តមានសុពលភាពបន្ទាប់ពីការបញ្ចប់លក្ខខណ្ឌនេះ និងនៅពេលបញ្ចប់សេវាទាំងអស់ពាក់ព័ន្ធនឹងលក្ខខណ្ឌនេះ។

យើងសូមប្រកាសថា យើងបានអាន យល់ និងយល់ព្រមតាមខចែង និងលក្ខខណ្ឌខាងលើ។

ចុះហត្ថលេខាដោយ ) …………………………………..

ឈ្មោះហត្ថលេខីដែលមានការអនុញ្ញាត និង ) …………………………………..

មុខតំណែង ) …………………………………..

ត្រាក្រុមហ៊ុន ) …………………………………..

នៅចំពោះមុខ៖- ) …………………………………..